# ជំពូក ១២

# ប្រទេសខ្មែរនៅសតវត្សទី ១៧ និង ១៨
## វិបត្តិក្នុងរាជវង្សខ្មែរ និងការជ្រៀតជ្រែករបស់យួន

មកដល់សតវត្សទី ១៧ ប្រទេសខ្មែរបានបើកទំព័រប្រវត្តិសាស្ត្រថ្មីមួយដែលពោរពេញទៅដោយមេរៀនជូរចត់ សំរាប់អោយបច្ឆាជនខ្មែរយកទៅត្រិះរិះពិចារណារកហេតុផល ហើយទាញយកការពិសោធន៍ពីសកម្មភាពរបស់ដូនតាខ្លួន ក្នុងបំណងធ្វើយ៉ាងណាកុំអោយធ្លាក់ទៅក្នុងរឿងចាស់ដដែលទៀត ។

## ក. ប្រតិកម្មប្រឆាំងសៀម និងចំណងមេត្រីភាពជាមួយយួន

### ១. ព្រះបរមរាជាទី ៨ ស្រីសុរិយោពណ៍ (១៦០៣-១៦១៨)

រួចមកហើយ យើងបានឃើញថា ប្រភពអឺរ៉ុប និងប្រភពខ្មែរបានផ្តល់ពត៌មានប្លែកគ្នាបន្តិចអំពីការដែលព្រះ **ស្រីសុរិយោពណ៌** វិលត្រឡប់ចូលមាតុប្រទេសវិញ ។ ប៉ុន្តែរាជពង្សាវតារខ្មែរទាំងអស់បាននិយាយស្របគ្នាថា ដែលព្រះ **ស្រីសុរិយោពណ៌** បានធ្វើមាតុភូមិនិវត្តន៍នោះ គឺដោយសាការមានសំណូមពរពីព្រះអយ្យការបស់ព្រះអង្គចំពោះព្រះចៅសៀម ក្នុងបំណងអោយស្តេចអង្គនេះបានមកគ្រប់គ្រងអាណាប្រជានុរាស្ត្រជាជំនួស **ព្រះកែវហ្វ៉ាចៅពញាញោម** ដែលជាស្តេចមិនប្រកបដោយទសពិធរាជធម៌ ។

កាលដែលព្រះ **ស្រីសុរិយោពណ៌** យាងមកដល់ប្រទេសភ្លាម ព្រះអង្គយាងទៅគង់នៅ **កោះស្លាកែត** (ទល់មុខនឹងជ្រោយអំពិលសព្វថ្ងៃ) ។ **សម្តេចព្រះទេវីក្សត្រី សម្តេចព្រះកែវហ្វ៉ា** និងព្រះរាជវង្សានុវង្សក៏បានយាងទៅគង់នៅមូលនៅទីនោះដែរ ។

### ១.១. ទំនាក់ទំនងជាមួយយួន

ប៉ុន្តែគួរគប្បីបញ្ជាក់ដែរថា ទោះបីព្រះអង្គទ្រង់បានបញ្ចូលឥទ្ធិពលសៀមមកក្នុងប្រទេសខ្មែរ ក៏ដោយ ក៏ព្រះ **ចរមរាជាស្រីសុរិយោពណ៌** ទ្រង់បាននឹកគិតទៅដល់អនាគតរបស់ប្រទេសជាតិដែរ ។ ព្រះអង្គទ្រង់បានឈ្វេងយល់ថា ឥទ្ធិពលរបស់សៀមមកលើប្រទេសព្រះអង្គនោះមានទម្ងន់ខ្លាំងក្លាណាស់ ។ ម៉្លោះហើយ ដើម្បីដោះប្រទេសអោយចេញផុតពីក្រញាំឥទ្ធិពលសៀមនោះ ព្រះអង្គពុំបានធ្វើការទាក់ទងជាមួយជនជាតិអឺរ៉ុបដូចព្រះរាជាមុនៗទៀតទេ តែព្រះអង្គបានទៅចងស្ពានមេត្រីជាមួយយួនម្តងវិញ ដោយទ្រង់មានបំណងយកឥទ្ធិពលយួននេះទៅទប់ទល់នឹងឥទ្ធិពលសៀម ។

គួរគប្បីជ្រាបថា ក្រោយពីបានរំដោះខ្លួនចេញផុតពីនឹមចិនអស់រយៈពេលជាងមួយពាន់ឆ្នាំមក (១១១មុន គ.ស.- គ.ស. ៩២៣) ស្តេចយួនក្នុងរាជវង្ស **លី** បានផ្តើមការវាយលុកប្រទេស **ចម្ប៉ា** ចាប់ពី ស.វ.ទី ១១ តទៅ ។ នៅគ.ស. ១៤៧០ ស្តេចយួនព្រះនាម **ឡេ ថាញ់តោន** (Lê Thanh Tôn) ទ្រង់វាយយកបានរាជធានី **វិជ័យ** របស់ចាមដែលនៅពេលនោះមានពលទាហានស្លាប់ដល់ទៅ ៤០ ០០០នាក់ ។ ជោគជ័យដ៏ធំសម្បើមនេះរបស់ជនជាតិយួនបានរុញច្រានព្រំប្រទល់ប្រទេស **ចាម្ប៉ា** ចុះឆ្ពោះមកទិសខាងត្បូងទៀត គឺមកដល់ជ្រោយ Varella ។ នៅគ.ស.១៦០០ ប្រទេសយួនត្រូវបាត់បង់ឯកភាពរបស់ខ្លួន : ទឹកដីត្រូវបែងចែកជាពីរ ខាងជើងជារបស់រាជវង្ស **ឡេ** (Lê) ដែលមានពួកស្តេចត្រាញ់ **ទ្រិញ** (Trinh) ជាអ្នកគាំទ្រ ខាងត្បូងត្រូវបានទៅពួកស្តេចត្រាញ់ **ង្វៀន** (Nguyên) ។ ប៉ុន្តែទោះបីមានវិបត្តិផ្ទៃក្នុងក៏ដោយ ក៏ពួកង្វៀង បានបន្តការវាយដណ្តើមយកទឹកដីប្រទេស **ចាម្ប៉ា** ទាល់តែអស់រលីង ។ ក្នុងក្របខ័ណ្ឌពង្រីកទឹកដីនេះ យួនបានវាយយក :

- **ភូ យេន** (Phu-yên) នៅគ.ស.១៦១១
- **ខាញ់ ហ៊ា** (Khanh - hoa) នៅគ.ស.១៦៥១
- **ប៊ិញ ធ្វឹន** (Binh - thuân) នៅគ.ស.១៦៩៣

ដូច្នេះ យើងឃើញថានៅស.វ.ទី ១៧នេះ យួនបានក្លាយជាមហាអំណាចមួយជាអ្នកនៅជិតខាងរបស់ខ្មែរយើង ។ គឺក្នុងកាលៈទេសៈនោះហើយដែលព្រះ **ចរមរាជាស្រីសុរិយោពណ៌** បានទៅចងសម្ពន្ធមេត្រីជាមួយយួនដោយស្តីដណ្តឹងបុត្រីស្តេចយួន ដើម្បីរៀបរាជាអភិសេកជាមួយព្រះរាជបុត្រច្បង នាម **ជ័យជេដ្ឋា** ។ តាមរាជពង្សាវតារខ្មែរ ក្សត្រីយួនអង្គនេះមាននាមថា **អង្គចូវ** ហើយនេះជាព្រឹត្តិការណ៍មួយមានសារៈសំខាន់ខ្លាំងណាស់ផង តែគួរអោយស្តាយ ! ព្រោះឯកសារយួនពុំមានកត់ត្រា រឿងនេះអោយបានច្បាស់លាស់សោះ ។ បើតាមប្រវត្តិសាស្ត្រយួនម្នាក់ថា ក្នុងឯកសារមួយឈ្មោះ Liêt Truyên Tiên Biên ត្រង់វគ្គនិយាយពីក្សត្រីបាននិយាយថា ស្តេច **ហ៊ី តុង** (Hy-Tông) មានបុត្រី ៤ នាក់ក្នុងចំណោម

នោះបុត្រី ២ នាក់គឺនាង **ង៉ុក លៀន** (Ngoc Liên) និង **ង៉ុក ដាញ់** (Ngoc Danh) គេឃើញមានកត់ត្រាច្បាស់លាស់ពីប្រវត្តិប្ដី និងកូន ចំណែកឯបុត្រីពីរនាក់ទៀតគឺ **ង៉ុក វ៉ាន** (Ngoc Van) និង **ង៉ុក ខ្វា** (Ngoc Khoa) គេមិនស្គាល់ច្បាស់ពីប្រវត្តិប្ដី និងកូនយ៉ាងណាទេ ។ អ្នកប្រវត្តិសាស្ត្ររូបនោះបានចោទសួរនៅទីបញ្ចប់ថា បើដូច្នោះ តើនាងណាមួយត្រូវជាមហេសីរបស់**ជ័យជេដ្ឋាទី២** ? (37) ។ ប៉ុន្តែបើតាមអ្នកនិពន្ធយួនម្នាក់ទៀត លោកអះអាងថា **ជ័យជេដ្ឋាទី២** បានរៀបរាជាភិសេកជាមួយនាង **ង៉ុក វ៉ាន** ជាបុត្រីរបស់ស្ដេច **ង្វៀន សៃ វឿង** (Nguyên Sai Vuong) ដែលបានសោយរាជ្យពីគ. ស. ១៦១៣ ដល់ ១៦៣៥ (38) ។ ត្រង់នេះគួរគប្បីបញ្ជាក់ថា នៅតំបន់ **ធ្វឹន ហ៊ា** (Thuân Hoa) នៅក្រុង **វេ** សម័យនោះមានស្ដេចមួយអង្គសោយរាជ្យពី ១៦១៣ ដល់ ១៦៣៥ ពិតមែន ។ ស្ដេចអង្គនេះ នៅមាននាមមួយទៀតថា **ង្វៀន ភុក ង្វៀន** (Nguyên Phuc Nguyên) ហើយពេលឡើងសោយរាជ្យទ្រង់មានព្រះនាមថា **ហ៊ី តុង ហៀន វ៉ាន់ ហ៊ាង ដេ** (Hy-Tông Hiên Vãn Hoang - dê) ។ បើដូច្នោះ មហេសីរបស់ **ជ័យជេដ្ឋា** គឺពិតជាបុត្រីរបស់ស្ដេចអង្គនេះហើយ តែយើងមិនហ៊ានសន្និដ្ឋានថា ត្រូវនឹងនាងណាមួយក្នុងចំណោមនាងទាំងពីរ គឺ **ង៉ុក វ៉ាន** និង **ង៉ុក ខ្វា** ។

មានចំណុចមួយទៀតដែលគួរអោយបញ្ជាក់ដែរថា បើតាមឯកសារយួន (37) គឺ **ជ័យជេដ្ឋា**អង្គឯងទេ ដែលបានទៅស្ដីដណ្ដឹងបុត្រីស្ដេចយួនដោយសង្ឃឹមថានឹងបានការគាំទ្រពីស្ដេចក្រុង**វេ** ដើម្បីទប់ទល់នឹងការគំរាមកំហែងរបស់សៀម ។ ការអះអាងនេះ ឃើញថាសមហេតុសមផលគួរជឿបានដែរ ព្រោះរាជាភិសេករវាងព្រះ **ជ័យជេដ្ឋា** និងក្សត្រីយួនបានប្រារព្ធធ្វើឡើងនៅគ. ស. ១៦២០ គឺនៅពេលព្រះអង្គទ្រង់បានឡើងសោយរាជ្យបាន ២ឆ្នាំហើយ(១៦១៨) ។ ប្រភពដដែលបានបន្ថែមទៀតថា ដែលស្ដេចយួនព្រមលើកបុត្រីថ្វាយ **ជ័យជេដ្ឋា** ព្រោះព្រះអង្គបានគិតវែងឆ្ងាយណាស់ !

## ១.២. ទំនាក់ទំនងជាមួយជនជាតិអឺរ៉ុប

ចំពោះទំនាក់ទំនងជាមួយជនជាតិអឺរ៉ុប ខ្មែរបានស្គាល់ជនជាតិអង់គ្លេសជាលើកដំបូងនៅគ. ស. ១៦១២ ព្រោះនៅឆ្នាំនោះជនជាតិអង់គ្លេសទី១ ឈ្មោះ Peter Floris បានធ្វើដំណើរតាមដងទន្លេមេគង្គ ហើយបានមកដល់ក្រុងភ្នំពេញនៅខែកក្កដា ។ ក៏ប៉ុន្តែរហូតមកដល់គ. ស. ១៦៥១ ទើបក្រុមហ៊ុនឈ្មោះ Engligh East India Company (ក្រុមហ៊ុនអង់គ្លេសនៅប្រទេសឥណ្ឌាខាងកើត) បានយកចិត្តទុកដាក់ខ្លាំងក្នុងការធ្វើជំនួញជាមួយប្រទេសខ្មែរ (39) ។

## ២. ព្រះបាទជ័យជេដ្ឋាទី២ (១៦១៨-១៦២៨)



*ចេតិយនៅលើភ្នំព្រះរាជទ្រព្យ (ដកស្រង់ចេញពីសៀវភៅ សិក្សាសង្គមថ្នាក់ទី ១១ ទំព័រ ១៨៧ បោះពុម្ពឆ្នាំ២០០០)*

ព្រះ**ជ័យជេដ្ឋា** បានឡើងសោយរាជ្យនៅ គ.ស. ១៦១៨ ដោយមានព្រះនាមសំរាប់រាជ្យថា **សម្តេចព្រះរាជឱង្ការព្រះជ័យជេដ្ឋាធិរាជរាមាធិបតី** ។ អ្នកប្រវត្តិសាស្ត្រនិយមហៅព្រះអង្គថា **ព្រះជ័យជេដ្ឋាទី ២** ។ ព្រះអនុជត្រូវបានតាំងជាមហាឧបរាជហើយទទួលព្រះនាមថា ព្រះ **ឧទ័យបរមរាជា** ។ ឯព្រះបិតាលោកគង់នៅជាឧភយោរាជ ប៉ុន្តែ នៅឆ្នាំក្រោយព្រះអង្គក៏សោយទិវង្គតទៅក្នុងព្រះជន្មាយុ ៦៤ វស្សានៅព្រះរាជវាំង **លង្វែក** ។

ព្រះបាទ **ជ័យជេដ្ឋាទី២** ទ្រង់បានបោះបង់ចោលនូវទំនៀមទំលាប់សៀម ហើយលើកយកទំនៀមទំលាប់ខ្មែរមកប្រើជំនួសវិញ ហើយដើម្បីបង្ហាញអោយសៀមឃើញថាព្រះអង្គមិនទទួលស្គាល់នូវអំណាចរបស់សៀមមកលើប្រទេសខ្មែរទេ ព្រះអង្គក៏លើករាជធានីពី **លង្វែក** ទៅតាំងនៅក្រុង **ឧដុង្គ** នៅគ.ស.១៦២០ ។ នៅគ.ស. ១៦២៣ ព្រះអង្គទ្រង់បញ្ជាអោយសាងព្រះចេតិយធំឈ្មោះព្រះ**ចេតិយត្រៃត្រឹង** នៅលើភ្នំព្រះរាជទ្រព្យដើម្បីតំកល់ព្រះអដ្ឋិធាតុព្រះបិតា ។

ក្នុងរជ្ជកាលព្រះអង្គ ព្រះបាទ **ជ័យជេដ្ឋាទី២** ទ្រង់បញ្ញត្តិអោយបណ្តាមុខមន្ត្រីធំតូច និងបណ្តានាយមហាតលិក នាយពល និងទូលឆ្លើយអោយថា **សម្តេចព្រះនារាយណ៍នរនាថ** ។ ព្រះអង្គទ្រង់លើកអ្នក**អង្គចូវ** ព្រះរាជបុត្រីស្តេចយួនអោយឡើងជាអគ្គមហេសីហៅ **សម្តេចព្រះតគវតីព្រះស្រីវរក្សត្រី** ។

ក្នុងរជ្ជកាលព្រះអង្គ មានការផ្ទៀងផ្ទាត់រៀបរៀងព្រះរាជក្រិត្យ២៤ក្រម មានក្រម **សុតាធិបតី** ក្រម **ឧសតរិយា** ក្រម **ចែកពល** ក្រម **ឧទេន** ក្រម **សុរទសខ្យ** ក្រម **ពលទេព** ក្រមស្នូស្តី ។ល។ (29) ។

កាលដែលមិនទាន់សោយរាជ្យ ព្រះជន្មបាន ២៦ វស្សា ព្រះ **ជ័យជេដ្ឋា** មានបុត្រ :

- នាម **ចៅពញាតូ** ជាមួយ **អ្នកម្នាងសុខ**
- នាម **ចៅពញានូ** ជាមួយ **អ្នកម្នាងនង** ។

លុះសោយរាជ្យបាន ២ឆ្នាំ ព្រះអង្គមានបុត្រ :

- នាម **ចៅពញាចន្ទ** ជាមួយ **អ្នកម្នាង** លាវឈ្មោះ **ចិស**

រាជពង្សាវតារខ្មែរខ្លះនិយាយថា ព្រះអង្គមានបុត្រី ២អង្គទៀត :

- នាម **ចន្ទវតីក្សត្រី** ជាមួយ **អ្នកម្នាងនង**

- នាម **ចុឡាវតី** ជាមួយអគ្គមហេសីយួន (?)

ចំណែកឯព្រះ **ឧទ័យបរមរាជា** មហាឧបរាជ ព្រះអង្គទ្រង់បញ្ញត្តិអោយបណ្តាមុខមន្ត្រីទូល និងឆ្លើយថា ព្រះ **ភូធរនរនាថ** ។ ស្តេចមានម្នាង ៣នាក់ ហើយមានបុត្រ ៤អង្គដូចតទៅ :

- **អ្នកអង្គនន់** បុត្រជាមួយ **អ្នកម្នាងសន**

- **អ្នកអង្គសូរ** បុត្រជាមួយ **អ្នកម្នាងសួស**

- **អ្នកអង្គតន់** បុត្រជាមួយ **អ្នកម្នាងសួស**

- **អ្នកអង្គអិម** បុត្រជាមួយ **អ្នកម្នាងអិន** ។

## ២.១. ទំនាក់ទំនងជាមួយសៀម

ដោយព្រះបាទ **ជ័យជេដ្ឋាទី ២** ពុំព្រមទទួលស្គាល់អំណាចរបស់សៀមមកលើប្រទេសខ្មែរ ព្រះចៅសៀមក៏លើកទ័ពចូលវាយខ្មែរនៅគ.ស.១៦២២ ។ ទ័ពសៀមបានលើកមកដល់ភ្នំ **ចុង្កាន** (បរិបូណ៌) ព្រះអង្គនាំទ័ពទៅតស៊ូប្រឆាំងនឹងកងទ័ពខ្លាំង ។ សៀមបាក់ទ័ព ត្រូវខ្មែរចាប់បានជាឈ្លើយអស់ជាច្រើន ហើយព្រះអង្គអោយហៅឈ្លើយទាំងនោះថា **សៀមចុង្កាន** ។ នៅគ.ស.១៦២៣ សៀមបានលើកទ័ពមកវាយខ្មែរម្តងទៀតក្រោមបញ្ជាការរបស់ព្រះចៅ **ស្រីធម្មរាជា** ។ លើកនេះ ទ័ពជើងទឹករបស់សៀមបានមកដល់ស្រុក **ពាម** ហើយបានពើបប្រយុទ្ធនឹងទ័ពរបស់ព្រះ **ឧទ័យ** ដែលចេញពីក្រុងឧដុង្គមានជ័យ ។ សៀមចាញ់បាក់ទ័ពថយទៅវិញអស់ទៀត ។ រាជពង្សាវតារខ្មែរខ្លះបញ្ជាក់ថា ក្រោយមកព្រះចៅសៀមទ្រង់ចាត់អោយបុត្រនាមព្រះ **ជេដ្ឋា** លើកទ័ពតាមជើងទឹកមកវាយខ្មែរម្តងទៀត ។ ព្រះ **ឧទ័យ** ត្រូវចាត់អោយចេញតទល់ទៀត សៀមមិនហ៊ានច្បាំងលើកទ័ពថយ ។ ព្រះ **ឧទ័យ** ទ្រង់សុំចូលវាយស្រុកសៀមតែព្រះ **ជ័យជេដ្ឋាទី ២** ទ្រង់មិនអនុញ្ញាត ។

## ២.២. ទំនាក់ទំនងជាមួយយួន

សៀវភៅប្រវត្តិសាស្ត្រយួនបានបញ្ជាក់ថា ប្រទេសខ្មែរ (ចឹងឡាប) ដែលស្ថិតនៅត្រង់វាលទំនាបខាងក្រោមនៃទន្លេមេគង្គ ជាប្រទេសមួយសម្បូណ៌ទៅដោយផ្លូវទឹក ឯដីធ្លីស្រែចំការក៏មានច្រើនណាស់

ដែរ ។ ចំណែកឯនៅប្រទេស **អាណ្ណាម** ឯណោះប្រជារាស្ត្រត្រូវពើបប្រទះនិងទុរភិក្សជារឿយៗ ។ ដោយស្រែចំការពុំបានផ្ដល់ផលអោយគ្រប់គ្រាន់ ម្យ៉ាងទៀតនៅពេលនោះ ពួកស្ដេចក្រាញ់ **ទ្រិញ** និង **ង្វៀង** កំពុងតែវាយប្រហារគ្នា ម្ល៉ោះហើយមានជនជាតិយួនជាច្រើនបានលបលួចចូលនៅក្នុងទឹកដីខ្មែរ ត្រង់ **បារា** និង **ដូនណៃ** ដើម្បីឆ្ការព្រៃយកដីធ្វើស្រែ (40) ។

នៅគ.ស. ១៦២៣ គណៈបេសកកម្មទូតយួនមួយត្រូវបានបញ្ជូនមកក្រុង **ឧដុង្គ** ក្នុងគោលបំណងសូមព្រះរាជាខ្មែរអនុញ្ញាតអោយយួនបង្កើតគ្រឹះស្ថានជំនួញនៅខាងត្បូងប្រទេសខ្មែរ គឺនៅត្រង់តំបន់ **ព្រៃគរ** (ព្រៃនគរ) **កំពង់ក្របី** (១) ព្រមទាំងសូមអនុញ្ញាតអោយមានសិទ្ធិកាន់កាប់ក្រសួងគយនៅតំបន់នោះផង ។ ស្ថានការណ៍ក្នុងប្រទេសសម្ព័ន្ធមិត្តជាមួយក្រុង **វេ** ការយោគយល់ដល់អគ្គមហេសីទាំងនេះហើយជាកត្តាជម្រុញអោយព្រះ **ជ័យជេដ្ឋាទី២** ទ្រង់អនុញ្ញាតយល់ព្រមតាមសេចក្ដីស្នើសុំរបស់គេ ។ ចំពោះរឿងនេះ អ្នកប្រវត្តិសាស្ត្របរទេសខ្លះយល់ឃើញថា : "ជាការវាយដណ្ដើមយកមណ្ឌលពាណិជ្ជកម្មមួយរបស់ខ្មែរដោយលាក់មុខ " (41) ។ ចាប់តាំងពីពេលនោះមក ហើយដោយមានការលើកទឹកចិត្តពីព្រះចៅក្រុង **វេ** ផង ជនជាតិយួនបានដឹកកូនជញ្ជូនចៅ បបួលគ្នាចូលនៅក្នុងទឹកដីខ្មែរ កាន់តែច្រើនឡើងៗ ។ បន្ទាប់មកទៀត ដោយយកលេសថា ដើម្បីជួយអាជ្ញាធរខ្មែររក្សាសន្តិសុខអោយមានប្រសិទ្ធិភាព ព្រះចៅក្រុង **វេ** ទ្រង់បានបញ្ជូនមេទ័ពម្នាក់អោយទៅឈរនៅតំបន់នោះទៀត ។

ចំពោះការដែលយួនលើកគ្នាចូលរស់នៅក្នុងទឹកដីខ្មែរជាលើកដំបូងនេះ មានរាជពង្សាវតារខ្មែរខ្លះនិយាយថា ស្ដេចយួនបានចាត់ទូតអោយមកសុំខ្ចីដីខ្មែរត្រង់**ព្រៃនគរ- កំពង់ក្របី** ដើម្បីហ្វឹកហាត់ទាហានធ្វើចម្បាំងជាមួយចិន ហើយនឹងបង្វិលសងមកខ្មែរវិញក្រោយរយៈពេល ៥ឆ្នាំ ។

គួរគប្បីជ្រាបថា ពួកយួនចំណូលថ្មីទាំងនោះ កាលដែលមកតាំងនៅក្នុងប្រទេសខ្មែរ ច្រើនតែទៅរស់នៅត្រង់កន្លែងណាដែលមានដីជាតិល្អដូចជានៅតាមច្រាំងទន្លេនិងស្ទឹងទាំងឡាយ ដែលជាមូលហេតុបណ្ដាលអោយជនជាតិខ្មែរសុខចិត្តលះបង់ចោលនូវទ្រព្យសម្បត្តិ មានស្រែចំការ ផ្ទះសំបែង ស្រុកភូមិ ដើម្បីថយខ្លួនទៅរស់នៅឯកន្លែងផ្សេង ព្រោះពុំអាចរស់នៅជាមួយពួកចំណូលថ្មីដែលមានទំនៀមទំលាប់ របៀបរស់នៅខុសប្លែកពីគ្នាពេក ។

នៅពេលដែលព្រះបាទ **ជ័យជេដ្ឋា** ទ្រង់សោយទិវង្គតទៅ នៅ គ.ស.១៦២៨ ភូមិភាគចាប់ពី **ព្រៃនគរ បារា** និង **ដូនណៃ** (កំពង់ស្រកាត្រី) ទៅទល់និងអតីតរាជាណាចក្រ **ចាម្ប៉ា** មានសុទ្ធតែជនជាតិយួនមកនៅពាសពេញអស់ទៅហើយ ។

---

(១). គួរគប្បីជ្រាបថា ដែលហៅថា ***ព្រៃគរ***(ព្រៃដើមគរ) នៅពេលនោះគឺត្រូវនិងតំបន់ ***ចិឡឹង*** សព្វថ្ងៃ ឯកន្លែងក្រុង***ព្រៃនគរ*** សព្វថ្ងៃពីដើមហៅថា ***កំពង់ក្របី***។

## ២.៣. ទំនាក់ទំនងជាមួយជនជាតិអឺរ៉ុប

ចាប់ពីស.វ. ទី ១៧តទៅ ខ្មែរបានទាក់ទងជាមួយជនជាតិអឺរ៉ុបថ្មីៗ ទៀត ជាពិសេសជនជាតិ **ហុល្លង់** នេះឯង ។

ផ្ទុយពីពួកព័រទុយកែល និងអេស្ប៉ាញដែលមានបំណងធំក្នុងការផ្សាយសាសនានៅអាស៊ី ពួកហុល្លង់ធ្វើសកម្មភាពតែក្នុងវិស័យជំនួញ ។ ចាប់ពីគ.ស. ១៥៩៥ ពួកនេះបានផ្តើមធ្វើប្រតិបត្តិការសឹកឆ្ពោះទៅ **កោះជ្វា** ហើយបន្ទាប់មកបានដណ្តើមយកពីពួកព័ទុយកែល និងអេស្ប៉ាញនូវអាណានិគមទាំងអស់លើកលែងតែ Macao ចេញ ហើយបានបង្កើតគ្រឹះស្ថានជំនួញនៅប្រទេសឥណ្ឌា នៅកោះសេរីលង្កា នៅ Malacca នៅប្រទេសសៀម និងនៅប្រទេសជប៉ុន ។

នៅគ.ស.១៦២០ ពួកហុល្លង់បានចូលមកធ្វើការទាក់ទងជាមួយខ្មែរជាលើកដំបូង : នៅថ្ងៃទី ២២ ខែ សីហា ឈ្មួញឈ្មោះ Jacob Gaerman ជិះកប៉ាល Galias បានមកដល់ពាមទន្លេមេគង្គ ហើយបានធ្វើដំណើរអស់រយៈពេល ៤ខែទើបមកដល់ក្រុងភ្នំពេញ ។ បីឆ្នាំក្រោយមកទៀត ពួកនេះបានបង្កើតគ្រឹះស្ថានជំនួញជាលើកដំបូងនៅ**កំពង់ឈ្នួល** ជិតរាជធានី **ឧដុង្គ** ។ ប៉ុន្តែ ឯកសារមួយទៀត (39) បាននិយាយថាការបង្កើតគ្រឹះស្ថានដំបូងនេះ គឺនៅគ.ស.១៦៣៧ ទៅវិញដោយ **ក្រុមហ៊ុនឥណ្ឌាខាងកើត** (Vereenigde Oostindische Compagnie) នៅខាងជើង **ពញាឮ** បន្តិច ។ តាំងពីពេលនោះមក ពួកហុល្លង់តែងតែព្យាយាមរកលេសមួលបង្កាច់ និងដាក់កំហុសលើពួកព័រទុយកែល ដោយមានជំនួយពីពួកជប៉ុន ។ ប៉ុន្តែ ទោះបីពួកហុល្លង់ខិតខំយ៉ាងណាក៏ដោយ ក៏គេមិនអាចកំចាត់ពួកចិនបានទេ ដែលនៅទីបំផុតទៅក្លាយជាឈ្មួញជើងឯកនៅតំបន់អាស៊ីអាគ្នេយ៍យើងនេះ ។

# ៣. ព្រះបាទស្រីធម្មរាជាទី ២ ឬ ព្រះរាជសំភារ ចៅពញាតូ(១៦២៩-១៦៣៤)

កាលព្រះជន្ម២១វស្សា **ចៅពញាតូ** បានយាងទៅបួសនៅឯ **នគរវត្ត** ។ ព្រះបិតាទ្រង់បានទំនុកបំរុងផ្សំផ្គុំជាមួយបុត្រីនាម **ចន្ទវតី** អោយជាជាយាកំណាន់ព្រះទ័យ ទ្រង់គិតថា នឹងបង្វែររាជសម្បត្តិថ្វាយនៅពេលណាដែលចាកសិក្ខាបទមក ។ ត្រង់ចំណុចនេះ ឯកសារខ្លះនិយាយថា បុត្រីដែលព្រះអង្គបានផ្សំផ្គុំអោយ **ចៅពញាតូ** នោះគឺ **ចុន្ទាវតី** ជាបុត្រីជាមួយ **អន្តចូវ** (?)ទៅវិញ ។

កាលដែលព្រះ **ឈានជ័យជេដ្ឋា** សោយទិវង្គតទៅ ពួកនាម៉ឺនបានយាងព្រះអនុជរបស់ព្រះអង្គគឺព្រះ**ឧទ័យ** អោយឡើងសោយរាជ្យសម្បត្តិ តែព្រះអង្គប្រកែកពុំព្រមសោះឡើយព្រះអង្គគ្រាន់តែទទួលឋានៈជាឧភយោរាជកាន់កាប់អំណាចបណ្តោះអាសន្នទំរាំមានព្រះរាជាឡើងសោយរាជ្យ (១៦២៨-១៦២៩) ។ ជាអកុសល ព្រះ**ឧទ័យ** បានគួចព្រះហឫទ័យប្រតិព័ទ្ធលើរូបនាង **ចន្ទវតី** (ឬបុប្ផាវតី ?) ដែលត្រូវជាគូកំណាន់របស់ **ចៅពញាតូ** ទៅវិញ ។

ចំណែកឯង**ចៅពញាតូ** ដែលកំពុងតែបួសនៅ **នគរវត្ត** នោះទាល់តែមាននាម៉ឺនទៅសូមយាងអស់ច្រើនលើក ទើបព្រមចាកសិក្ខាបទមកទទួលរាជាភិសេកឡើងសោយរាជ្យស្នងព្រះបិតាដោយយកព្រះនាមថា **ព្រះបាទសម្តេចព្រះស្រីធម្មរាជាធិរាជរាមាធិបតី** នៅរាជធានី **គោះឃ្លោក** (ខ្សាច់កណ្តាល) ។

នៅគ.ស. ១៦៣៣ ព្រះបាទ **ធម្មរាជាទី២** ទ្រង់បានលើកទ័ពទៅវាយលុកចូលក្រុង **នគររាជសីមា** តែយកមិនបាន ហើយក៏កៀរគ្រួសារខ្លះនាំចូលស្រុកខ្មែរវិញ ។ ក្នុងរជ្ជកាលរបស់ព្រះអង្គ មានការតែងតាំងចិន ៤នាក់ជាមន្ត្រី និងការបង្ហាត់ចិនអោយទៅជាទាហានក្រុមរក្សាព្រះអង្គ ។

គួរគប្បីជ្រាបថា ព្រះបាទ **ធម្មរាជាទី២ ចៅពញាតូ** ជាក្សត្រមួយអង្គមានប្រាជ្ញាយកព្រះទ័យទុកដាក់នឹងអក្សរសាស្ត្រ ។ ព្រះអង្គបានទុកស្នាព្រះហស្តជាច្រើនក្នុងវិស័យនេះ ដូចជា :

- **រាជសំពូ "ច្បាប់រាជសំភារ "** (គ.ស. ១៦២២)
- **ហេមន្តមាស** (គ.ស. ១៦២៩)
- **កាព្យនិរាស** (គ.ស. ១៦៣០)
- **ហិនលក្ខណ៍សល** (គ.ស. ១៦៣០) (30)

ប៉ុន្តែព្រះអង្គពុំបានសោយរាជ្យអោយបានយូរអង្វែងដើម្បីផ្សព្វផ្សាយ និង ឧបត្ថម្ភវិស័យអក្សរសាស្ត្រនេះអោយបានទូលំទូលាយ និងបានរឹងប៉ឹងទេ ព្រោះព្រះអង្គមានទំនាស់វិបត្តិជាមួយនឹងព្រះបិតុលាក្នុងរឿងស្នេហា ! យ៉ាងណាមិញ ភ្លើងកាមតណ្ហាបានដុតរោលព្រះអង្គអោយចាប់ព្រះទ័យប្រតិព័ទ្ធ នាង **ចន្ទវតី ( ឬ បុប្ផាវតី ? )** ឡើងវិញ ។ គូសង្សារទាំងពីរបានសរសេរលិខិតឆ្លើយឆ្លងគ្នា ។ នាង **ចន្ទវតី ( ឬ បុប្ផាវតី ? )** បានធ្វើឧបាយបែកចិនទៅ **នគរវត្ត** ដើម្បីបានឱកាសជួបគ្នា ។ ក្រោយមក នាងធ្វើឧបាយជាបានបន់ស្រន់ព្រះពុទ្ធនៅ **វត្តព្រះវិហារសួគ៌** អោយព្រះភស្តាបានជាសះស្បើយកាលដែលព្រះអង្គប្រឈួន ដល់ពេលចេញដំណើរក៏ចូលទៅ **គោះឃ្លោក** ជួបព្រះ **ធម្មរាជា** ទៀត ។ ពួកមន្ត្រីចាំបាត់យូរពេក ត្រឡប់មកទូលព្រះ**ឧទ័យ** ព្រះអង្គលើកទ័ពទៅដោយមានពួកព័រទុយក័លទៅជាមួយផង ។

ខាងព្រះ**ធម្មរាជា** ក៏លើកទ័ពចេញទទួលច្បាំង តែទន់ដៃជាងក៏រត់ចូលបន្ទាយ បន្ទាយត្រូវវាយបែកទៀត ។ ព្រះ **ធម្មរាជា** ទ្រង់គៀសព្រះអង្គតាមទូកទៅដល់ស្រុក **គញ្ជរ** រត់ទៅពួនលើចុងត្នោត ហើយត្រូវពួកព័រទុយក័លបាញ់ធ្លាក់មកដី តែមុននិងសុគត (គ.ស. ១៦៣៤) ទ្រង់បានសុំអនុញ្ញាតទុកពេលចារលើស្លឹកត្នោតនូវដំបូន្មាន ទុកអោយបច្ឆាជនជាន់ក្រោយកុំល្មោភក្នុងកាមតណ្ហាដូចព្រះអង្គទៀត ។

ចំណែកឯងនាង **ចន្ទវតី** (ឬ **បុប្ផាវតី** ?) ត្រូវទទួលទោសប្រហារជីវិតបង់ ។

## ៤. ព្រះបាទអង្គទងរាជា ចៅពញានូ (១៦៣៥-១៦៣៩)

**ចៅពញានូ** ជាព្រះរាជបុត្រព្រះបាទ **ជ័យជេដ្ឋាទី២** ព្រះជន្មបាន ២៣វស្សា បានឡើងសោយរាជសម្បត្តិស្នងព្រះរៀមនៅក្រុង **ឧដុង្គមានជ័យ** ដោយមានព្រះនាមសំរាប់រាជ្យថា **ព្រះបាទសម្តេចព្រះអង្គទងរាជាធិរាជរាមាធិបតី** ។

នៅគ.ស. ១៦៣៨ នៅស្រុក **រលាំងគ្រើល** មានការបះបោរ ព្រះអង្គអោយប្រាមប្រាបរាបទាបអស់ទៅវិញ ។

### ៤.១. ទំនាក់ទំនងជាមួយជនជាតិហុល្លង់

នៅគ.ស.១៦៣៥ ពួកហុល្លង់បានចាប់យកសំពៅរបស់ខ្មែរដែលផ្ទុកពេញដោយទំនិញក្នុងដែនទឹក Macassar ។ ព្រះ **អង្គទងរាជា** ទ្រង់បានតវ៉ា ពួកហុល្លង់ក៏បានលែងសំពៅនោះមកវិញ ។ នៅឆ្នាំបន្ទាប់ កប៉ាល់ហុល្លង់ពីរគ្រឿងមកពីក្រុង **បាតាវីយ៉ា** (គឺក្រុង **ជាកាតា** សព្វថ្ងៃ) បាននាំសំបុត្ររបស់លោកទេសាភិបាលស្នើលក់កាំភ្លើងធំអោយខ្មែរ ។ ជាអកុសលកប៉ាល់មួយគ្រឿងឈ្មោះ Noordwych ត្រូវគឿងជាប់លើខ្សាច់ត្រង់មាត់ពាមទន្លេមេគង្គ ។ ព្រះរាជាទ្រង់បានបញ្ជាអោយរឹបអូសយកកាំភ្លើងធំ៣០ដើម និងស្ពាន់៥០០ហាបពីកប៉ាល់នោះ ។ នៅថ្ងៃទី២៦ ខែមីនា ១៦៣៧ លោកទេសាភិបាល ហុល្លង់នៅក្រុង **បាតាវីយ៉ា** បានបញ្ជូនឈ្មួញឈ្មោះ Hendrik Hagenhaar ជាមួយនឹងកប៉ាល់ ៤គ្រឿងទៀត មកក្នុងឋានៈជាទូតដើម្បីផ្សះផ្សាវិវាទខាងលើ ។ តែលុះមកដល់ទន្លេមេគង្គនៅថ្ងៃ ១១ ខែឧសភា លោក Hagen-haar បានជួបប្រទះនិងកប៉ាល់ព័រទុយកាល់មួយគ្រឿង ហើយក៏បានរឹបអូសយកកប៉ាល់ នោះទៅជាហេតុបណ្តាលអោយព្រះរាជាស្តីបន្ទោសលោកយ៉ាងខ្លាំងនៅពេលដែលលោកថ្វាយសារតាំងចំពោះព្រះអង្គ ។ នៅគ.ស. ១៦៣៨ គណៈបេសកកម្មថ្មីមួយទៀតត្រូវបញ្ជូនមក **ឧដុង្គ** ក្រោមកិច្ចដឹកនាំរបស់លោក Paulus Croocq ហើយលោក Johannès Van Hagen បានមកជំនួសលោក Jan Galen ជាមេគ្រឹះស្ថានហុល្លង់ ។ ពួកមកថ្មីនេះក៏ពុំបានទទួលផលល្អក្នុងកិច្ចការរបស់ខ្លួនដូចពួកមកមុនៗដែរ ។ ប៉ុន្តែ ពួកនេះបានធ្វើអោយព្រះ **ឧទ័យ** យកព្រះទ័យទុកដាក់យ៉ាងខ្លាំងក្នុងទំនាក់ទំនង ពាណិជ្ជកម្ម និងហេរញ្ញវត្ថុជាមួយពួកហុល្លង់ ។ នៅគ.ស.១៦៣៨ ព្រះអង្គទ្រង់បានអោយ **ក្រុមហ៊ុន ឥណ្ឌាខាងកើត** ខ្ចីប្រាក់ និងលក់ម្រក្សណ៍ ឈើខ្លឹមចន្ទន៍ និងភ្លុកដំរី អោយពួកហុល្លង់ (9) ។

### ៤.២. ទំនាក់ទំនងជាមួយយួន

រាជពង្សាវតារខ្មែរខ្លះបាននិយាយថា នៅគ.ស.១៦៣៨ (?) **ព្រះអង្គទងរាជា** ទ្រង់បានតឿនទារយកដី **ព្រៃនគរ -កំពង់ក្របី** មកវិញ ប៉ុន្តែអគ្គមហេសីយួនរបស់ **ព្រះជ័យជេដ្ឋាទី២** ទ្រង់បានធ្វើអន្តរាគមន៍សុំអោយពន្យារពេលអោយបានយូរបន្តិចទៀត ។

## ៥. ព្រះបាទបទុមរាជា អង្គនន់ (១៦៣៩-១៦៤១)

លុះព្រះ **អង្គទងរាជា** សោយទិវង្គតទៅនៅគ.ស.១៦៣៩ ព្រះ **អង្គនន់** រាជបុត្រច្បងព្រះ**ឧទ័យ** ព្រះជន្មបាន ២១វស្សា ត្រូវបានលើកអោយឡើងសោយរាជ្យស្នងព្រះរៀមនៅរាជធានី **ឧដុង្គ** ដោយមានព្រះនាមសំរាប់រាជ្យថា **ព្រះបាទសម្តេចព្រះបរមរាជាធិរាជរាមាធិបតី** ។ ព្រះអង្គទ្រង់យកព្រះរាជបុត្រីសម្តេច **ព្រះជ័យជេដ្ឋាទី២** ដែលត្រូវជាព្រះអនុជព្រះអយ្យកា១ ជាព្រះអគ្គមហេសីលើកព្រះនាមហៅ **សម្តេចព្រះតគចតីព្រះចវក្សត្រី** (ឯកសារសៀមថាឈ្មោះ **អ្នកយ៉ា**) ។ ព្រះអង្គទ្រង់មានបុត្រជាមួយអគ្គមហេសីនេះនាម **ស្រីជ័យជេដ្ឋ** ។ ឯព្រះបិតា គឺព្រះ**ឧទ័យ** ទ្រង់គង់នៅជាព្រះឧភយោរាជដដែល ។

នៅគ.ស. ១៦៤១ **ចៅពញាចន្ទ** ព្រះរាជបុត្រពៅព្រះ **ជ័យជេដ្ឋាទី២** ដោយអន់ព្រះទ័យព្រោះមិនបានឡើងសោយរាជ្យ បានអោយបក្សពួកចូលលុកព្រះរាជវាំងធ្វើគុតបានទាំងសម្តេចឧភយោរាជ និងព្រះ **បទុមរាជា** ។

# ខ. វិបត្តិក្នុងរាជវង្សខ្មែរ និងអន្តរាគមន៍របស់យួន

បទឧក្រិដ្ឋដែល **ចៅពញាចន្ទ** ទ្រង់បានប្រព្រឹត្តនោះ បណ្តាលអោយវិបត្តិជាថ្មីទៀតក្នុងរាជវង្សខ្មែររហូតដល់មានចម្បាំងគ្នាឯងក្នុងស្រុក ហើយដែលជាឱកាសល្អអោយយួនលូកដៃចូលជ្រៀតជ្រែកក្នុងផ្ទៃក្នុងរបស់ខ្មែរជាលើកដំបូង ។

## ១. ព្រះបាទរាមាធិបតីទី ១ ចៅពញាចន្ទ (១៦៤១-១៦៥៩)

ក្រោយពីបានធ្វើគុតព្រះបិតុលា និងព្រះអនុជអយ្យកា១ហើយ **ចៅពញាចន្ទ**បុត្រពៅ **ព្រះជ័យជេដ្ឋាទី២** បានឡើងសោយរាជសម្បត្តិនៅក្រុង **ឧដុង្គមានជ័យ** ដោយមានព្រះនាមសំរាប់រាជ្យថា **ព្រះបាទសម្តេចព្រះរាមាធិបតី** នៅពេលដែលព្រះជន្មបាន ២៣វស្សា ។

រាជពង្សាវតារខ្មែរបាននិយាយថា ថ្ងៃមួយព្រះអង្គយាងទៅក្រសាលនៅទន្លេធំ និង **ស្រីសន្ធរ** ដល់ពេលត្រឡប់មកវិញដល់ កំពង់ហ្លួង ទ្រង់ទតឃើញស្រីចាម (ជ្វា?) ឈ្មោះនាង **ទ័ះ** (ឯកសារខ្លះថា ឈ្មោះ Fatima) ហើយដោយត្រូវពួកចាមដាក់ស្នេហ៍បន្ថែមផង ក៏ទ្រង់ប្រតិព័ទ្ធយ៉ាងខ្លាំងលើរូបនាង **ទ័ះ** ហើយលើកនាងជាស្នំឯកទៀតផង ប៉ុន្តែប្រពៃណីតម្រូវអោយព្រះអង្គកាន់ សាសនាឥស្លាម កាត់ចុងអង្គជាតិ និងយកព្រះនាមថា Ibrahim ។ ដោយហេតុនោះហើយ ទើបមានឈ្មោះហៅថាព្រះ **រាមចូលសាសន៍** ។ ព្រះអង្គទ្រង់បានប្រោសប្រណីពួកចាមជ្វា លើកតំកើងអោយឡើងជានាម៉ឺនធំៗ ទ្រង់បានលើក **ចៃសុន** (ព្រះបិតាក្មេក) អោយឡើងជា **សម្តេចបរទេសរាជ** ។

## ១.១. វិវាទជាមួយពួកហុល្លង់

នៅពេលដែលបានឡើងសោយរាជ្យ **ព្រះរាមាធិបតី** ទ្រង់បានផ្ញើព្រះរាជសារលិខិតទៅជូនលោកទេសាភិបាលហុលល្លង់នៅ **បាតាវីយ៉ា** ដើម្បីសុំធ្វើការទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹង **ក្រុមហ៊ុននៃប្រទេសឥណ្ឌាខាងកើត** ។ ជាការឆ្លើយតប លោកទេសាភិបាលបានបញ្ជូនលោក Cornelius Clain អោយមកប្រទេសខ្មែរនៅគ.ស.១៦៤២ ដើម្បីថ្វាយពរសរសើរចំពោះព្រះអង្គដែលទ្រង់មានជ័យជំនះលើពួកស្តេចជ្រែករាជ្យ(ព្រះឧទ័យ និងអង្គនន់) និងដើម្បីសូមអោយព្រះអង្គប្រុងប្រយ័ត្នចំពោះពួកព័រទុយក័លកាន់សាសនាកាតូលិក ។

ឯកសារមួយទៀតបាននិយាយថា នៅគ.ស.១៦៤១ លោក Van Wuystoff បានធ្វើដំណើរតាមទន្លេមេគង្គទៅដល់ក្រុង **វៀងចន្ទន៍** ដោយឆ្លងកាត់តាមក្រុង **ភ្នំពេញ** ក្នុងដំណើរស្វែងរកទិញជ័រកំញាន និងល័ក្ខ ។ បើតាមពត៌មានដែលឈ្មួញហុល្លង់ ឈ្មោះ Indijk បានផ្តល់ថា នៅសម័យនោះគេអាចទិញនៅភ្នំពេញជារៀងរាល់ឆ្នាំនូវស្បែកប្រើស ១០០ ០០០ ផ្ទាំង មាស ភ្លុកដំរី និងជ័រកំញាន ។ ចំណែកឯទំនិញដែលគេនាំចូលពីប្រទេសក្រៅមានជា អាវ ស្ពាន់ ព័រសីឡែន និងកំរាលព្រំមកពីស្រុក Coromandel (39) ។

នៅខែ កញ្ញា ១៦៤៣ ឧប្បត្តិហេតុមួយបានកើតឡើង ។ លោក Pierre de Regemortes មេគ្រឹះស្ថានជំនួញហុល្លង់បានតវ៉ាចំពោះព្រះរាជាពីការខូចខាតដែលក្រុមហ៊ុនលោកបានទទួលរងគ្រោះ ។ ដោយលោកនេះបានបញ្ចេញឫកពារកោងកាចពេក ពួកក្រុមរក្សាព្រះរាជាក៏បានសម្លាប់លោក និងពួកបរិវាររបស់លោកទៅ ។ នៅពេលជាមួយគ្នា គ្រឹះស្ថានរបស់លោកក៏ត្រូវគេប្លន់រឹបអូសយកទ្រព្យសម្បត្តិអស់ មនុស្ស ៣៦ នាក់ ត្រូវស្លាប់ហើយមនុស្សប្រហែល ៥០ នាក់ទៀតត្រូវចាប់យកទៅឃុំឃាំង ។

ដើម្បីជាការសងសឹក **ក្រុមប្រឹក្សាប្រទេសឥណ្ឌា** (Conseil des Indes) បានបញ្ជូនកងនាវាមួយនៅថ្ងៃ ២៣ ខែមីនា ១៦៤៤ ក្រោមបញ្ជាការរបស់លោក Heindrik Harouze និងលោក Simon Jacobsz

Domkens ។ កងនាវាដែលមានកប៉ាល់ ៥ គ្រឿង និងទាហានទាំងអស់ ១៦០នាក់ បានមកដល់ក្រុងចតុមុខនៅថ្ងៃ ៦ ខែកក្កដា ហើយស្ថិតនៅទីនោះរហូតដល់ថ្ងៃទី ២០ ខែមករា ១៦៤៥ ដោយពុំបានទទួលសំណងសោហ៊ុយជួសជុលពីព្រះរាជាខ្មែរសោះ ។ ម្ល៉ោះហើយមេបញ្ជាការក៏សំរេចថា ត្រូវតែបន្តដំណើររហូតដល់រាជធានី **ឧដុង្គ** ។ ពេលដែលពួកហុល្លង់ទៅដល់ ទ័ពខ្មែរបានយកសំរាស់ឫស្សីទៅឃាំងផ្លូវទឹកហើយយកកាំភ្លើងធំទៅភ្ជង់ពីលើច្រាំងទាំងសងខាង ។ ការប្រយុទ្ធតទល់គ្នាក៏បានផ្ទុះឡើង ។ លោកមេបញ្ជាការត្រូវស្លាប់ ឯពួកពលទាហានហុល្លង់ក៏ស្លាប់អស់ជាច្រើន ។ ប៉ុន្តែកងនាវាបានខំពុះពារឧបសគ្គរត់រំដោះខ្លួនបាន ហើយនៅគ.ស. ១៦៤៦-១៦៤៧ ពួកហុល្លង់បានធ្វើការចរចាសុំសន្តិភាពជាមួយខ្មែរ ។ ព្រះរាជាទ្រង់បានយល់ព្រមអោយដោះលែងពួកឈ្លើយហុល្លង់ និងសងទៅវិញនូវទំនិញដែលបានរឹបអូស ។ នៅគ.ស. ១៦៥៥ កិច្ចព្រមព្រៀងមួយត្រូវបានសំរេចឡើងជាមួយ **ក្រុមហ៊ុនប្រទេសឥណ្ឌាខាងកើត** ដោយមានការជួសជុលសោហ៊ុយដល់គ្រឹះស្ថានជំនួញហុល្លង់ដែលត្រូវខូចខាតយ៉ាងដំណំនោះ ។

## ១.២. ទំនាក់ទំនងជាមួយយួន

ព្រះ **រាមាធិបតីទី១** ទ្រង់បានតឿនទារយកដី **ព្រៃនគរ - កំពង់ក្របី**ពីយួនមកវិញ ព្រះអគ្គមហេសីយួនរបស់ព្រះ **ជ័យជេដ្ឋា** បានធ្វើអន្តរាគមន៍ជាថ្មី ដោយសុំពន្យារពេលអោយបានយូរតទៅទៀត ។

នៅពេលដែលព្រះអង្គទ្រង់រាជ្យបាន ១៧ វស្សា គឺនៅគ.ស. ១៦៥៨ ព្រះ**អង្គសូរ** និងព្រះ**អង្គតន់** ដែលជារាជបុត្រព្រះ **ឧទ័យ** ហើយដែលបានគេចផុតពីឧក្រិដ្ឋកម្មពីមុននោះ ក្រោយពីបានចាត់មន្ត្រីអោយទៅបញ្ចុះបញ្ចូលរាស្ត្រជាសម្ងាត់ បានលើកទ័ពទៅច្បាំងជាមួយព្រះ **រាមាធិបតី** តែច្បាំងមិនឈ្នះក៏រត់ទៅពឹងពាក់ និងអតីតអគ្គមហេសីយួនរបស់ព្រះ **ជ័យជេដ្ឋាទី ២** ។ ក្សត្រីយួននេះមានព្រះទ័យក្រេវក្រោធយ៉ាងខ្លាំងចំពោះ **រាមាធិបតី** ក៏បានទូន្មានស្តេចខ្មែរទាំងពីរអង្គអោយសុំជំនួយពីព្រះចៅក្រុងវេ ។

ត្រង់នេះ អ្នកប្រវត្តិសាស្ត្រយួនមានយោបល់ថា ជាឱកាសមួយយ៉ាងប្រសើរដើម្បីអោយពួកស្តេច **ង្វៀង** ធ្វើអន្តរាគមន៍ ពង្រីកឥទ្ធិពលរបស់ខ្លួនលើប្រទេសខ្មែរដែលដូនតាគេបានយកចិត្តទុកដាក់ជាយូរមកហើយ (37) ។ ស្តេច **ថៃ តុង** (Thai - tông) បានបញ្ជាអោយលើកទ័ព ៣០០០នាក់ មកជួយតាមសំណូមពររបស់ស្តេចខ្មែរ ។ ទ័ពយួនលើកមកប្រយុទ្ធនឹងទ័ពខ្មែរនៅត្រង់ **ឃារា** ចាប់បាន **ព្រះរាមាធិបតី** ដាក់ទ្រុងដែកនាំយកទៅឃុំនៅ **ក្វាងប៊ិញ** (Quang Binh) ឯ **អង្គអិម** ជាបុត្រព្រះ**ឧទ័យ** ដែរ តែចូលដៃខាង **ព្រះរាមាធិបតី** ត្រូវក្ស័យព្រះជន្មលើសមរភូមិនោះទៅ ។

ចំពោះ**ព្រះរាមាធិបតី** ឯកសារខ្លះ ថាយួនឃុំព្រះអង្គទុករហូតដល់សុគត (36) ឯកសារខ្លះថាត្រូវលែងអោយមកវិញ យាងមកបានពាក់កណ្ដាលផ្លូវប្រឈួនហើយសុគតនៅស្រុក **ចត់ចិញ្ជៀន** ឯកសារខ្លះទៀតថាត្រូវលែងមកវិញតែត្រូវលើកស្លួយសារអាករថ្វាយស្ដេចយួន និងត្រូវការពារជនជាតិយួនដែលរស់នៅលើទឹកដីខ្មែរ (40) ។

លុះមានជ័យជំនះលើ **ព្រះរាមាធិបតិ** ហើយ ទ័ពយួនបែរមកច្បាំងនឹង**អង្គសូរ** និង **អង្គតន់** វិញ ។ ស្ដេចទាំងពីរស៊ូច្បាំងឈ្នះ ដេញទ័ពយួនរត់វិលចុះទៅស្រុកវិញ ។

## ២. ព្រះបរមរាជាទី ៩ អង្គសូរ (១៦៥៩-១៦៧២)

ក្រោយពីដេញទ័ពយួនអោយថយទៅវិញអស់ទៅ **អង្គសូរ** រាជបុត្រព្រះ **ឧទ័យ** បានឡើងគ្រងរាជ្យនៅ **ឧដុង្គមានជ័យ** ក្នុងជន្មាយុ ២៦ វស្សា ។

ព្រះអង្គទ្រង់លើក **អង្គឡី** ក្សត្រីជាព្រះអនុជ(មាតាដទៃ) ជាព្រះទេពី ។ ព្រះអង្គនៅមានម្នាង២ទៀតគឺ :

- **អ្នកម្នាងពៅ** មានបុត្រានាម **អ្នកអង្គជី** និង បុត្រីនាម **អង្គស្រីធីតា**
- **អ្នកម្នាងឆៃ** មានបុត្រានាម **ចៅពញាសូរ** (ឯកសារខ្លះថាឈ្មោះ **អង្គស៊ូ**) និងបុត្រីនាម **អង្គអី** ។

លុះបានព្រះជន្ម២៩ វស្សា ព្រះអង្គទ្រង់ធ្វើពិធីប្រាប្ដាភិសេកឡើងសោយរាជសម្បត្តិ ដោយមានព្រះនាមសំរាប់រាជ្យថា **សម្ដេចព្រះបរមរាជាធិរាជរាមាធិបតី** ។ព្រះអង្គទ្រង់លើក **អង្គឡី** ជាអគ្គមហេសីព្រះនាមហៅ **សម្ដេចព្រះតគចតីព្រះចមក្សត្រី** ។

នៅគ. ស. ១៦៦៧ គ្រឹះស្ថានជំនួញពួកហុល្លង់នៅ **កំពង់ល្ហួង** ដែលបានបើកធ្វើសកម្មភាពឡើងវិញនោះ ត្រូវពួកចិននៅជិតខាងប្លន់យកទ្រព្យសម្បត្តិអស់ ។ ទោះបីយ៉ាងហ្នឹងហើយក៏ដោយ ក៏គ្រឹះស្ថាននោះនៅបន្តសកម្មភាពរបស់ខ្លួនតទៅទៀតយ៉ាងត្រដាបត្រដួសក្រោមកិច្ចដឹកនាំរបស់លោក Johannès Besselman ។ គេដឹងថា គ្រឹះស្ថានជំនួញនោះត្រូវបិទជាស្ថាពរនៅគ. ស. ១៦៨២ ហើយចាប់ពីពេលនោះទៅ ទំនាស់រវាងពួកព័រទុយក័ល និងពួកហុល្លង់ក្នុងវិស័យជំនួញក៏ផុតរលត់អស់ទៅ ។

គ្រានោះ មានជនម្នាក់តាំងខ្លួនជាស្ដេចឈ្មោះ **ឆារ៉ែន** គិតដណ្ដើមរាជ្យ ។ ព្រះអង្គទ្រង់បញ្ជាអោយលើកទ័ពទៅបង្ក្រាប ហើយចាប់បានយកមកប្រហារជីវិតបង់ ហើយទ្រង់តាំង **អង្គតន់** ព្រះអនុជជាឧភយោរាជ ។

នៅគ. ស. ១៦៧២ ព្រះអង្គទ្រង់សព្វព្រះទ័យផ្សំផ្គុំបុត្រីនាម **អង្គស្រីធីតា** និងក្មួយនាម **ស្រីជ័យជេដ្ឋ** ជាបុត្រព្រះ**អង្គននំទី ១** ។ ប៉ុន្តែជាអកុសល គឺបុត្រប្រសា និងក្មួយអង្គនេះបានបញ្ជូនបក្សពួកអោយចូលក្នុងរាជវាំង លួចធ្វើគុតព្រះអង្គបានប៉ុន្មានខែក្រោយមក ។

ចំណែកឯព្រះឧភយោរាជ **អន្តតន់** ច្បាំងចាញ់ក៏ភៀសព្រះអង្គទៅស្រុកយួនជាមួយក្មួយនាម **អន្តនន់** (បុត្រអង្គអិម) ។

## ៣. ព្រះបទុមរាជាទី ២ ស្រីជ័យជេដ្ឋ (១៦៧២-១៦៧៣)

**ព្រះស្រីជ័យជេដ្ឋ** ព្រះជន្មបាន ៣៣ វស្សា បានឡើងសោយរាជសម្បត្តិនៅក្រុង **ឧដុង្គមានជ័យ** ដោយមានព្រះនាមសំរាប់រាជ្យថា **ព្រះបាទសម្តេចព្រះបទុមរាជាធិរាជរាមាធិបតី** ។ ព្រះអង្គយក **អន្តឡី** អគ្គមហេសីព្រះ**អន្តសូរ** ហើយត្រូវជាព្រះមាតុច្ឆា ជាអគ្គមហេសីរបស់ព្រះអង្គ ។

លុះសោយរាជ្យបាន ៥ ខែ សម្តេចព្រះ **តគទតីព្រះចមក្សត្រី** ជាអគ្គមហេសីអោយពួកចាមជ្វាលបធ្វើគុតព្រះអង្គបាន ។

## ៤. ព្រះកែវហ្វាទី ២ អង្គជី (១៦៧៣-១៦៧៥)

ព្រះ**អន្តជី** បុត្រព្រះ **បរមរាជាទី ៩ អន្តសូរ** ត្រូវបានលើកអោយសោយរាជ្យក្នុងព្រះជន្មាយុ ២១ វស្សា នៅក្រុង **ឧដុង្គមានជ័យ** ដោយមានព្រះនាមសំរាប់រាជ្យថា **សម្តេចព្រះកែវហ្វា** ។

ព្រះអង្គមានម្នាងម្នាក់ ឈ្មោះអ្នកម្នាង**ពៅ** ។ ពីកាលពុំទាន់សោយរាជ្យនោះអ្នកម្នាង**ពៅ** បានប្រសូតបុត្រា ១ អង្គនាម **ចៅពញាយ៉ង** (ឯកសារខ្លះហៅថា **ព្រះអន្តយ៉ង**) ។

នៅគ. ស. ១៦៧៣ គឺនៅពេលដែលព្រះអង្គឡើងសោយរាជ្យនោះ ព្រះឧភយោរាជ **អន្តតន់** និង **អន្តនន់** ដែលបានរត់ទៅពឹងយួនពីមុន បានលើកទ័ពយួន១០០០០នាក់ជាជំនួយរបស់ស្តេច **ថៃ តុង** (Thai Tông) ។ ព្រះ**កែវហ្វាអន្តជី** ដោយទ្រង់បារម្ភខ្លាចព្រះបិតុលា **អន្តតន់** ដណ្តើមយករាជសម្បត្តិ ក៏ទ្រង់លើកទ័ពចេញទទួលច្បាំងនៅភ្នំពេញតែមិនចាញ់មិនឈ្នះ ។ ព្រះ**អន្តតន់** ក៏ថយទ័ពទៅនៅត្រើយ **ល្វាឯម** ក្រោយមកលើកទ័ពចូលវាយបែកបន្ទាយភ្នំពេញ ហើយបំរុងលើកបង្ហួសទៅវាយ **ឧដុង្គ** ទៀត តែប្រឈួនហើយសោយទិវង្គតទៅ ។

ព្រះ**កែវហ្វាអន្តជី** លើកទ័ពទៅច្បាំងទៀត យួនបាក់ទ័ពត្រឡប់ទៅស្រុកវិញអស់ទៅ ។ ប្រទេសពេលនោះត្រូវចែកជាពីរ : ខាងលិចបានទៅ **ព្រះកែវហ្វា** ខាងកើតបានទៅ **ព្រះអន្តនន់** ដែលពួកមន្ត្រីថ្វាយព្រះនាមថា **សម្តេចព្រះបទុមរាជាមហាឧភយោរាជ** ។

**ព្រះកែវហ្វា** លើកទ័ពទៅច្បាំងទៀត តែប្រឈួនហើយសុគត ។ ឯកសារខ្លះថា ព្រះអង្គច្បាំងចាញ់យួន រត់ទៅសុគតនៅស្រុក **ថ្នាំតម្លឹង** ខែត្រ **សំរោងទង** (ក្បួនវត្តកោកកាក) ។ ឯកសារយួនថា ព្រះអង្គភៀសព្រះអង្គចូលព្រៃហើយត្រូវបក្សពួកធ្វើគុត (37) ។

ព្រះ**អង្គស៊ូ** ( ឬ**ចៅពញាសូរ**) ធ្វើចម្បាំងប្រឆាំង និងអង្គ**នន់** តទៅទៀត ។ ការប្រយុទ្ធគ្នាកើតឡើងនៅ **ពញាឮ** ។ ព្រះ**អង្គនន់** ឧភយោរាជទទួលបរាជ័យភៀសព្រះអង្គទៅស្រុកយួនម្តងទៀត ។ ក្នុងដំណើរនោះ អ្នកម្នាង**ឯម** ជាកូនចិន **ចុងគុន** បានប្រសូតបុត្រនាម **អង្គអិម** (នាមដូចព្រះអយ្យកោ) ។

គួរគប្បីបញ្ជាក់ថា ឯកសារយួនច្រើននិយាយថានៅគ.ស.១៦៧៤ **ព្រះអង្គឌី** (Nac Ong Dai) បានទៅសុំជំនួយទ័ពសៀមមកច្បាំងនឹង**អង្គនន់** (Nac Ong Nôn) (៣៧-៤០) ប៉ុន្តែឯកសារខ្មែរទាំងអស់ពុំបាននិយាយពីជំនួយទ័ពសៀមនោះសោះ ។ បើមានគឺ **អង្គស៊ូ** វិញទេជាអ្នកសុំជំនួយពីក្រុង **ស្រីអយុធ្យា** ក្នុងការបន្តចម្បាំងជាមួយ**អង្គនន់** ។ ម្យ៉ាងទៀត ឯកសារយួនបាននិយាយថា ព្រះ**អង្គស៊ូ** (Nac Ong Thu) បានចុះចូលនឹងយួនហើយដោយសារព្រះអង្គជាវង្សស្តេចពេញច្បាប់ក៏ត្រូវបានលើកអោយសោយរាជ្យ ចំណែកឯ **អង្គនន់** ត្រូវបានតាំងជាឧភយោរាជអោយឈរត្រួត **ព្រៃនគរ** ហើយត្រូវលើកសួយថ្វាយព្រះអង្គរៀងរាលឆ្នាំ (40) ។

## គ. ការបាត់បង់ទឹកដីកម្ពុជាក្រោម

### ១. ព្រះបាទជ័យជេដ្ឋាទី៣ អង្គស៊ូ ឬ ចៅពញាសូរ (រជ្ជកាលទី១ : ១៦៧៥-១៦៨៨)

លុះវាយកំចាត់ទ័ពយួនអោយថយទៅវិញអស់ **ព្រះអង្គស៊ូ** (ឬចៅពញាសូរ) ដែលមានព្រះជន្ម ១៦វស្សា បានឡើងសោយរាជ្យស្នងព្រះរៀមនៅក្រុង **ឧដុង្គមានជ័យ** ដោយមានព្រះនាមថា **សម្តេចព្រះស្រីជ័យជេដ្ឋា** ។ ព្រះអង្គទ្រង់លើក **អង្គលី** (អង្គអី ?) ព្រះអនុជរួមបិតា (ឯកសារខ្លះថាជាព្រះមាតុច្ឆា)(42) ជាអគ្គមហេសី ។

គួរគប្បីជ្រាបថា នៅគ.ស.១៦៧៩ មាននាម៉ឺនចិនឈ្មោះ **យឿង ង៉ាន ឌិច** (Duong Ngan Dich) និង **ត្រឹន ធឿង ស្វៀង** (Trân Thuong Xuyên) រត់មកពីខេត្ត **ក្វាង ឌុង - ក្វាងស៊ី** ព្រោះពេលនោះពួក **ម៉ង់ស៊ូ** (Mandchous) វាយយកបានប្រទេសចិននៃរាជវង្ស **មិញ** (Minh) ។ ដោយពុំព្រមចំណុះពួកបរទេសឈ្លានពានទឹកដី ពួកចិនទាំងនោះបាននាំគ្នា៣០០០នាក់ នឹងសំពៅ ៥០មកសុំជ្រកកោននឹងស្តេចយួន ។ ស្តេច **ថៃ តុង** (Thai Tông) ទ្រង់បានបញ្ជូនជនភៀសខ្លួននោះអោយទៅនៅក្នុងប្រទេសខ្មែរត្រង់តំបន់ **យ៉ាឌិញ** (ឧកញ៉ាឌិន ?) ។ ក្រោយមកពួកនោះ បានបំបែកគ្នាទៅនៅត្រង់ **ដូនណៃ** ខ្លះត្រង់ **មេសរ** ខ្លះ ប្រកបរបរធ្វើស្រែចំការ បង្កើតក្រុងមានឈ្មួញបរទេសចូលលក់ដូរយ៉ាងច្រើន គឺឈ្មួញជាតិអឺរ៉ុប ឈ្មួញជប៉ុន និងឈ្មួញជ្វា ។

គួរគប្បីជ្រាបថា នៅពេលដំណាលគ្នាជាមួយ និងជនជាតិចិនភៀសខ្លួនខាងលើនេះ មានចិនម្នាក់ទៀតឈ្មោះ **ម៉ាក គីវ** (Mac Cuu) មានកំណើតនៅខេត្ត **ក្វាង ឌុង** ជាឈ្មួញមានឈ្មោះល្បី ធ្លាប់ធ្វើសកម្មភាពជំនួញនៅប្រទេសហ្វីលីពីន និងនៅក្រុងបាតាវ្យានៅពេលដែលចិនច្បាំងចាញ់ពួក **ម៉ាន់ជូ** លោកមិនព្រមប្រកាន់យកទំនៀមទំលាប់បរទេសមានការក្រងសក់ជាដើម ក៏រត់មកជ្រកកោននឹងស្តេចខ្មែរ ហើយត្រូវបានតែងតាំងជាមន្ត្រីឈរត្រួតតំបន់ឆ្នេរឈូងសមុទ្រសៀម ។ ដោយឃើញផ្ទៃក្នុងរបស់ខ្មែរមានភាពច្របូកច្របល់ និងដោយឃើញឈ្មួញបរទេសចេញចូលច្រើន គាត់ក៏បើកក្បាលបៀយកគុង ។ ម្យ៉ាងទៀត ដោយជីកបានកំណប់មួយ គាត់ក៏ក្លាយទៅជាអ្នកមានស្តុកស្តម្ភ ។ គាត់បានសង់បន្ទាយនិងក្រុងនៅមាត់សមុទ្រ ហើយប្រមូលរាស្ត្រអោយទៅនៅត្រង់ **ពាម កោះត្រល់ កំពត កំពង់សោម ក្រមួនស ទឹកខ្មៅ** ។ នៅគ.ស.១៦៨៧-១៦៨៨ សៀមលើកទ័ពចូលវាយលុកតំបន់ **ពាម** ចាប់បាន **ម៉ាកគីវ** យកទៅប្រទេសសៀម តែក្រោយមកគាត់បានលួចរត់ត្រឡប់មក **ពាម**បានវិញនៅប្រមាណ គ.ស. ១៧០០ (37) ។

នៅគ.ស.១៦៨២ ព្រះ**អន្លនន់**ដែលបានភៀសព្រះអង្គទៅស្រុកយួននោះ ទ្រង់បានប្រមែប្រមូលពួកចិនដែលជាចំណូលថ្មីនៅ **ដុងណៃ - យ៉ាឌិញ** ផ្សំគ្នាជាមួយទ័ពយួនខ្លះ លើកទៅវាយព្រះ **ជ័យជេដ្ឋា** ទៀត ដំបូងវាយយកបានខេត្ត **ព្រះត្រពាំង បាសាក់** ហើយលើកបង្ហួសដល់ **ភ្នំពេញ - ឧដុង្គ** ។ កាលណោះព្រះ **ជ័យជេដ្ឋា** កំពុងតែគង់នៅវាំង **ទ្រនំជ្រឹង** ទ្រង់កែនទ័ពទៅច្បាំងឈ្នះ ទ័ពចិនក៏ថយទៅនៅ **កោះតែងអស់** ប៉ុន្តែពួកនោះបានចាប់ព្រះមាតាព្រះអង្គទៅឃុំទុកនៅ **ជ្រោយចង្វារ** ក្រោយមកបាន **ពញាឃុត** ទៅរំដោះបានមកវិញ ។

នៅគ.ស. ១៦៨៣ ព្រះ **ជ័យជេដ្ឋា** ទ្រង់យាងទៅគង់នៅ **ឧដុង្គមានជ័យ**វិញ ។

នៅគ.ស.១៦៨៤ **ព្រះអន្លនន់** ត្រឡប់មកពីស្រុកយួន មកតាំងបន្ទាយនៅ**ស្រីសន្ធរ** ហើយលើកទ័ពចំរុះខ្មែរ - ចិន ទៅវាយក្រុងភ្នំពេញ តែត្រូវបរាជ័យថយចូលបន្ទាយវិញ ។

នៅគ.ស. ១៦៨៨ ព្រះ**ជ័យជេដ្ឋា** ទ្រង់ប្រឈួនដោយជម្ងឺពិសក្តៅ (ឯកសារខ្លះកើតអុតធំ) ក៏ប្រគល់រាជសម្បត្តិថ្វាយព្រះមាតា ។

## ២. រជ្ជកាលអ្នកម្នាងទៃ (១៦៨៨)

ព្រះមាតាទ្រង់បានសោយរាជ្យជំនួសបាន៣ខែ ។ លុះព្រះ **ជ័យជេដ្ឋា** ទ្រង់បានជាសះស្បើយហើយ ចេញទ្រង់ព្រះផ្នួសបាន ៧ ថ្ងៃហើយលាមកឡើងសោយរាជ្យវិញ ។

## ៣. ព្រះជ័យជេដ្ឋាទី៣ (រជ្ជកាលទី២ : ១៦៨៨-១៦៩៥)

នៅគ.ស. ១៦៨៩ នាម៉ឺនឈ្មោះ **ចៅពញានូ** និងចិនឈ្មោះ **តាន់ចុងអឿ** ដោយតូចចិត្តមិនបានបុណ្យសក្តិ ក៏រត់ទៅចូលខាង **អង្គនន់** ព្រះអង្គអោយលើកទ័ពមកច្បាំង តាំងបន្ទាយនៅ **ស្រោយចខ្វារ** ។ ប៉ុន្តែ មន្ត្រីទាំងពីរត្រូវចាប់បានហើយយកទៅប្រហារជីវិតបង់ ។

នៅឆ្នាំដដែល ព្រះ **ជ័យជេដ្ឋា** ដែលបានគ្រងរាជ្យអស់រយៈពេល ១៣ឆ្នាំមកហើយ ក៏ទ្រង់ធ្វើរាជពិធីប្រាប្តាភិសេក ដោយយកព្រះនាមសំរាប់រាជ្យថា **សម្តេចព្រះជ័យជេដ្ឋាបរមសុរិន្ទរាជាធិរាជរាមាឥសូរ** លើក**អង្គលី** (អង្គអី ?) ជាអគ្គមហេសី ហៅថា **សម្តេចព្រះតគវតីសិរី ចក្រពត្តិមហាក្សត្រី** ។ ពេលនោះ **ព្រះអង្គនន់** បានភៀសទៅសុំជំនួយទ័ពយួនមកច្បាំងនឹងព្រះអង្គទៀត ។ ទ័ពយួនពីរម៉ឺននាក់បានលើកមកដល់ក្រុងភ្នំពេញ តែត្រូវបរាជ័យថយទៅស្រុកវិញអស់ ។ ចំណែកឯព្រះ **អង្គនន់** ទ្រង់រត់ចូលបន្ទាយ **ស្រីសន្ធរ** ការពារខ្លួន ។ ក្រោយមកដោយឈឺព្រះទ័យ ព្រោះបរាជ័យច្រើនដងពេក ក៏សុគតទៅក្នុងព្រះជន្មាយុ ៣៧វស្សា ។

ចំពោះប្រតិបត្តិការសឹករបស់យួនលើកនោះ ឯកសារយួនបានផ្តល់ពត៌មានថា ដោយយួនវាយសន្ធាប់ខ្លាំងពេក ព្រះ **អង្គស៊ូ** (Nac Thu) ទ្រង់បានថយចូលការពារក្នុងបន្ទាយ ព្រះអង្គទ្រង់បានបញ្ជាអោយ Nac Sa (?) នាំគ្រឿងបណ្ណាការទៅជូនមេទ័ពយួនឈ្មោះ **ម៉ាយ វ៉ាន់-ឡុង** (Mai Van Long) តែរាជទូតនោះត្រូវចាប់ឃុំជាឈ្លើយ ។ ដោយហេតុនោះព្រះអង្គបានបញ្ជាស្ត្រីរូបឆោមម្នាក់ឈ្មោះ Chiêm Dao Luât (?) ជាអ្នកមានវោហារថ្វីមាត់អោយយកវត្ថុមានតម្លៃដូចជាមាស ប្រាក់ជាដើមទៅជូនមេទ័ពយួនទៀត ។ មេទ័ពនោះ នៅតែតឿនអោយព្រះអង្គលើកសួយសារអាករទៅថ្វាយ ។ ព្រះអង្គមានបញ្ជាស្ត្រីដដែលនោះ អោយយកមាសប្រាក់ទៅសូកប៉ាន់ថែមទៀត និងសុំអោយរង់ចាំ ។ មេទ័ព Van Long ជឿពាក្យសន្យា មិនព្រមលើកទ័ពចូលវាយសោះ ។ មេទ័ពម្នាក់ទៀតឈ្មោះ **ង្វៀង ថាំងសឺន** (Nguyên Thang Son) ថ្វាយដំណឹងទៅស្តេចយួន ។ ព្រះអង្គទ្រង់ខ្ញាល់ខ្លាំង ចាត់អោយមេទ័ព **ង្វៀង ហ៊ីវ ហាវ** (Nguyên Huu Hao) ទៅជំនួស ។ មេទ័ពនោះបានលើកទ័ពទៅបោះជំរំនៅ Bich-Dôi (?) នៅគ.ស.១៦៩០ ។ ពេលនោះស្តេចយួនបញ្ជូនទូតអោយមកប្រាប់ថា : “ប្រសិនបើ **អង្គស៊ូ** (Nac Thu) ចង់រួចទោស ត្រូវលើកសួយមានដំរីឈ្មោល ៥០ មាស ៥០០តម្លឹង ប្រាក់ ២០០០តម្លឹង កុយរមាស៥០ ថ្វាយយ៉ាងប្រញាប់ បើពុំនោះទេត្រូវលើកទ័ពចូលវាយលុកភ្លាម ” ។ ព្រះ**អង្គស៊ូ** (Nac Thu) ទ្រង់បានបញ្ជាអោយយកដំរីតូច ២០ក្បាល មាស ១០០តម្លឹង ប្រាក់ ៥០០តម្លឹង ទៅជូន **ង្វៀង ហ៊ីវ ហាវ** ។ មេទ័ពយួនភាគច្រើនយល់ថា ព្រះ **អង្គស៊ូ** (Nac Thu) មិនស្មោះត្រង់ សុំចូលវាយលុក តែព្រះអង្គបានបញ្ជាអោយនាង Dao Luât (?) ទៅអង្វរករសុំ អោយពន្យារពេលទៀត ។ មេទ័ព **ង្វៀង ហ៊ីវ ហាវ** យល់ថាយួនមិនបាច់ច្បាំងផងក៏ស្តេចខ្មែរព្រមចំណុះទៅហើយ ដូច្នេះមិនបាច់វាយលុកធ្វើអ្វី ។ ចាប់ពី

ពេលនោះមកពួកមេទ័ពយួនបែកបាក់គ្នា ។ ព្រះ**អង្គសូ** (Nac Thu) ទ្រង់បញ្ជាអោយនាង Dao Luât (?) យកដង្វាយមានដំរីតូច ១០ក្បាល កុយរមាស ៦ មាស ៥០តម្លឹង ប្រាក់ ១០០ តម្លឹងទៅជូនជាបន្ថែមទៀត ។ ដោយហេតុនោះ ទោះបីពួក សេនាសុំវាយលុកយ៉ាងណាក៏ដោយក៏ **ង្វៀង ហ៊ឹវ ហាវ** ដកទ័ពថយទៅនៅត្រង់ **បារា** ។ ស្តេចយួន ខ្វាល់ខ្វាំង ទ្រង់ដកហូតបុណ្យសក្តិពីមន្ត្រីរូបនោះ ។

ឯកសារយួនដដែលបានបញ្ជាក់ទៀតថា ប្រតិបត្តិការសឹកលើកនោះឃើញថាបានទទួលផលល្អដោយព្រះ **អង្គសូ** (Nac Thu) ព្រមចំណុះ និងព្រមលើកសួយសារអាករថ្វាយ ។ ជនជាតិយួនចូលនៅក្នុងទឹកដីខ្មែរកាន់តែច្រើនឡើង ។ ទ័ពយួនយកដីនោះ (**ចៀងឌា - យ៉ាឌិញ**) ចែកជាតំបន់ ហើយចាត់មន្ត្រីអោយឈរត្រួតត្រាតែក្រៅផ្លូវការនៅឡើយ (37) ។

នៅគ.ស.១៦៩០ ព្រះ**ជ័យជេដ្ឋា** ទ្រង់មានបុត្រជាមួយ **អង្គលី** (អង្គអី ?) នាម **ឧទ្ធរាជា** លើក**អង្គយ៉ង** បុត្រព្រះ **អង្គជី** អោយនាមថា **ឧទ័យរាជា** ហើយផ្សំផ្គុំ និងព្រះ **សុជាតិក្សត្រី** (បុត្រីព្រះអង្គនន់) ជាជាយា ។ ព្រះឧទ័យរាជាមានបុត្រនាម **អង្គតន់** ដែលតមកទៀតមាននាមថា **អង្គឥម** ។

លុះស្រុកបានសន្តិភាពឡើងវិញហើយ ព្រះ**ជ័យជេដ្ឋា** ទ្រង់បញ្ជាអោយសើរើច្បាប់សំរាប់រដ្ឋហើយរៀបចំឡើងវិញ ដោយមានការបន្ធូរបន្ថយទណ្ឌកម្មដែលមានលក្ខណៈធ្ងន់ហួសប្រមាណ និងការបំបាត់ចោលនូវទោសប្រហារជីវិតបង់ផង ។ ម្យ៉ាងទៀត ព្រះអង្គក៏ទ្រង់បានរៀបចំអោយមានរូបមន្តសំរាប់ធ្វើសច្ចាប្រណិធានខាងនយោបាយ និងខាងតុលាការ ។

នៅគ.ស.១៦៩២ ស្តេចចាមនាម **បាត្រាញ់** (BaTranh) មិនព្រមលើកសួយសារអាករថ្វាយស្តេចយួន ។ ស្តេច**ង្វៀង ភុក ជូ** (Nguyên phuc Chu) បញ្ជាអោយមេទ័ព **ង្វៀង ហ៊ឹវ គិញ** (Nguyên huu Kinh) លើកទ័ពទៅវាយហើយចាប់បាន ។ រាជវង្សានុវង្សចាមនៅ **ផានរិច** (Phan-ri) **ផានរាំង** ( Phan-rang) ដោយមានបរិវារ ៥០០០នាក់ បានភៀសចូលមកសុំជ្រកកោននឹងព្រះ**ជ័យជេដ្ឋា** ។ ព្រះអង្គក៏ទ្រង់សន្តោសអោយទៅនៅ **ត្បូងឃ្មុំ** ខ្លះ **ស្ទឹងត្រង់** ខ្លះ **ជ្រោយចង្វារ** ខ្លះ **ព្រែកប្រា** ខ្លះ ។

នៅគ.ស.១៦៩៥ ព្រះអង្គទ្រង់បង្វែររាជសម្បត្តិអោយទៅព្រះភាគិនេយ្យ (ក្មួយ) ព្រះ**ឧទ័យរាជា** (បុត្រព្រះអង្គជី) ។

## ៤. ព្រះបាទរាមាធិបតីទី ២ អង្គយ៉ង (គ.ស.១៦៩៥-១៦៩៦)

ព្រះ **ឧទ័យរាជា** កាលមានព្រះជន្ម២១វស្សា ទ្រង់បានទទួលរាជសម្បត្តិពីព្រះបិតុលានៅក្រុង**ឧដុង្គមានជ័យ** ទ្រង់មានព្រះនាមថា ព្រះបាទសម្តេចព្រះ**នារាយណ៍រាមាធិបតី ព្រះឧទ័យរាជាបរមបពិត្រ** ។ ព្រះអង្គទ្រង់លើកព្រះ **សុជាតិវតី** ជាអគ្គមហេសី ។ ព្រះអង្គឡើងសោយរាជ្យបានតែ ១០ខែ ទ្រង់អាពាធ ហើយសោយទិវង្គតទៅ ។

## ៥. ព្រះបាទជ័យជេដ្ឋាទី៣ (រជ្ជកាលទី៣ : ១៦៩៦-១៦៩៩)

កាលដែលដាក់រាជ្យថ្វាយទៅព្រះ **ឧទ័យរាជា** នោះ ព្រះបាទ **ជ័យជេដ្ឋាទី៣** បានចេញទ្រង់ផ្នួសបាន ៥ថ្ងៃ រួចលាផ្នួសមកវិញ ។ លុះភាគិនេយ្យសោយទិវង្គតទៅ ព្រះអង្គឡើងសោយរាជ្យជាលើកទី ៣ ។

នៅគ.ស.១៦៩៧ ដោយមានព្រះបំណងប្រមែប្រមូលរាជវង្សានុវង្ស ព្រះអង្គទ្រង់បានបញ្ជានាម៉ឺនអោយលើកគ្រឿងបណ្ណាការទៅថ្វាយស្តេចយួន ដើម្បីសុំព្រះ **អង្គអិម** មកវិញ ។ ព្រះអង្គទ្រង់សព្វព្រះទ័យលើក **អង្គអិម** ជា **ព្រះកែវហ្វា** ហើយទ្រង់លើកបុត្រីព្រះអង្គព្រះនាម **សម្តេចព្រះមហាក្សត្រី** អោយជាទេពីទៀត ។ ក្រោយមក **ព្រះកែវហ្វា** មានបុត្រនាម **អង្គជី** (សម្តេចព្រះសត្ថា) ។

នៅគ.ស.១៦៩៩ **ឧកញ៉ានរិន្ទអិម** ជាកូន **ឧកញ៉ាមហាសេនាមិញ** ចូលចិត្តទូលញុះញង់មន្ត្រីឯទៀត ហើយមិនកោតខ្លាចព្រះចេស្តាផង ។ ព្រះរាជាទ្រង់ជេរបន្ទោសប្រដៅទូន្មានកុំអោយប្រព្រឹត្តអាក្រក់ទៀត ។ មន្ត្រីរូបនោះនឹកខ្មាសព្រះស្នំ រកឧបាយកលក្បត់ ធ្វើពុតជាឈឺ ថ្វាយត្រាលាងារចេញពីរាជការ រួចទៅធ្វើជំនួញនៅស្រុកក្រោមជួបនឹងមន្ត្រីយួនក៏និយាយញុះញង់ថា ស្តេចខ្មែរមិនប្រកបដោយធម៌ ហើយយកសៀមជាមិត្តគិតវាយយួន ។ ម្ល៉ោះហើយ មន្ត្រីរូបនោះក៏សុំអង្វរអោយយួនជួយទំនុកបំរុងខ្លួនជាជំនួយកងទ័ពដើម្បីលើកទៅវាយព្រះរាជា ។

ស្តេចយួនព្រះនាម **ហៀន តុង** (Hiên-tông) អោយលើកទ័ព ៤០០០០នាក់ និងទូក ៥០០ (ឯកសារខ្លះថាតែ ២០០០០នាក់ (42) ទៅរហូតដល់បឹងទន្លេសាប ។ ពេលនោះព្រះ **ជ័យជេដ្ឋា** និងពួកបរិវារភៀសទៅនៅពោធិ៍សាត់ ហើយកែនទ័ពប្រយុទ្ធនឹងយួនវិញ ។ ទ័ពខ្មែរត្រូវចែកជា២កង : ១ស្ថិតនៅក្រោមបញ្ជាការរបស់ព្រះ**ធម្មរាជា** ព្រះរាជបុត្រ ១ទៀតនៅក្រោមបញ្ជាការរបស់ព្រះ **អង្គអិម** ព្រះភាគិនេយ្យ ។ ទ័ពទាំង ២កង ជើងគោកនិងជើងទឹកលើកទៅប្រសប់គ្នានៅកំពង់ឆ្នាំង វាយផ្ទប់ហើយរុញច្រានទ័ពយួនអោយថយពីស្រុកខ្មែរតាមទន្លេមេគង្គ (42) ប៉ុន្តែវាពុំព្រមត្រឡប់ទៅស្រុកយួនវិញទេ បែរជាក្រាញនៅក្នុងដីខ្មែរត្រង់ **ព្រៃនគរ កំពង់ស្រកាត្រី បារា** ដែលលោក **ឧកញ៉ានរិន្ទអិម** បានសន្យាថាទុកជាថ្នូរនឹងជំនួយទ័ពយួនសំរាប់លោកវាយនឹងជាតិឯងនោះ (សូមមើលផែនទី) ។




ចាប់ពីពេលនោះមក ស្តេច**ហៀន តុង**បានបញ្ជាអោយលោក**ង្វៀង ហ៊ុយគិញ** ចូលមករៀបចំទឹកដីរបស់ខ្មែរដែលយួនទើបយកជាកម្មសិទ្ធិរបស់គេនោះ ។ លោកក៏យកស្រុក **ដូនណៃ** បង្កើតជាស្រុក **ភឿក ឡុង** (Phuoc-long) យកដី **បៀងហ៊ា** បង្កើតជាបន្ទាយ **ត្រឹង បៀន** (Trân Biên) យកដី **ព្រៃនគរ** បង្កើតជាស្រុក **តឹងប៊ិញ** (Tân-binh) យកដី **យ៉ាឌិញ** (ឧកញ៉ាឌិន ?) បង្កើតបន្ទាយ**ភៀន ត្រឹង** (Phiên Trân) ។ រួចស្តេចយួនបញ្ជាអោយប្រមែប្រមូលរាស្ត្រពី **ក្វាង ប៊ិញ** (Quang Binh) អោយចូលមករស់នៅលើទឹកដីថ្មី បង្កើតជាភូមិ ជាស្រុក និងស្ការដីធ្វើស្រែធ្វើចំការ ។ កាលណោះ ជនជាតិចិនក៏មានចំនួនកើនឡើងកាន់តែច្រើនហើយ យួនក៏បង្កើតស្រុកភូមិអោយពួកនោះរួចចាប់ផ្តើម**ធ្វើនយោបាយសមាន**កម្ម : ជនជាតិចិនដែលនៅត្រង់ដី **ត្រឹង បៀន** និង **ភៀន ត្រឹង** គេតម្រូវអោយចូលសញ្ជាតិយួនទាំងអស់ (37-40) ។

គួរគប្បីបញ្ជាក់ថា មន្ត្រីយួនទាំងប៉ុន្មានដែលមកឈរនៅត្រង់តំបន់ខាងលើនោះត្រូវឡើងទៅមេទ័ពម្នាក់ដែលកាន់កាប់អំណាចខាងយោធាផង និងអំណាចខាងរដ្ឋបាលផង ហើយដែលមានបញ្ជាការដ្ឋានតាំងនៅ **ព្រៃនគរ** ។

ចំណែកឯទឹកដីខ្មែរនៅត្រង់ **មេសរ** យួនបានដាក់អំណាចត្រួត្រាតែនៅក្រៅផ្លូវការនៅឡើយ ។

នៅដំណាច់គ.ស.១៦៩៩ **ព្រះជ័យជេដ្ឋា** ទ្រង់បង្វែរាជសម្បត្តិថ្វាយទៅព្រះ**កែវហ្វាអង្គអិម** ព្រះរាជបុត្រប្រសារដែលទ្រង់បានច្បាំងឈ្នះយួនហើយចាប់បានទាំង **ឧកញ៉ានរិន្ទអិម** ទៀតផង ។

## ៦. ព្រះកែវហ្វាទី៣ អង្គអិម (១៦៩៩-១៧០០)

ព្រះ **កែវហ្វាអង្គអិម** ឡើងសោយរាជ្យស្នងព្រះបិតុលា គង់នៅ**រាជវាំងតាក់** នៅពោធិ៍សាត់ ។ ចំណែកឯព្រះ**ជ័យជេដ្ឋា** កាលដាក់រាជ្យនោះ ព្រះអង្គចេញទ្រង់ផ្នួសនៅក្នុង **វត្តពោធិមានបុណ្យ** បាន ៣ថ្ងៃ ក៏លាផ្នួស ទើបសម្តេចព្រះ **កែវហ្វា** លើករាជសម្បត្តិថ្វាយព្រះអង្គ ព្រះអង្គទ្រង់ទទួលសោយរាជសម្បត្តិវិញ ។ ឯកសារខ្លះនិយាយថា ដោយយល់ថា ព្រះបិតាក្មេកមានគុណទើបព្រះ**កែវហ្វា** ថ្វាយរាជសម្បត្តិព្រះអង្គវិញ ប៉ុន្តែឯកសារខ្លះទៀតនិយាយថា ដោយព្រះអង្គគ្មានសមត្ថភាពគ្រប់គ្រងរដ្ឋ ទើបព្រះបិតាក្មេកយករាជ្យមកវិញ (9) ។

## ៧. ព្រះជ័យជេដ្ឋាទី៣ (រជ្ជកាលទី ៤ : ១៧០០-១៧០២)

ក្នុងរជ្ជកាលទី ៤នេះ មានការបះបោររបស់មន្ត្រីម្នាក់ឈ្មោះ **គិម** ដែលមានយួនគាំទ្រ ។ ដំបូងព្រះអង្គត្រូវភៀសទៅពោធិ៍សាត់ជាមួយពួកបរិវារ ក្រោយមកមានជ័យជំនះ ហើយចាប់បានមេបះបោរនោះទៀត (9) ។

ឯកសារយួនមួយនិយាយថា នៅគ.ស. ១៧០០ មេទ័ពជាតិចិនឈ្មោះ **ត្រឹន ធឿនស្វៀន** (Tràn Thoung Xuyên) ដែលបានបំរើស្តេចយួននោះ បានច្បាំងឈ្នះខ្មែរច្រើនលើក(ជួយគាំទ្រមន្ត្រីឈ្មោះគិមនោះឬ ?) បានលើកទ័ពមកដល់បន្ទាយ Bich-dôi (?) និងភ្នំពេញ ។ **អន្តស៊ូ** (Nac Thu) ដកថយ បន្ទាយត្រូវវាយបែក ពួកសេនាទាហានសុំចុះចាញ់ មេទ័ព **ង្វៀន ហ៊ីវ គិញ** ចូលបន្ទាយលួងលោមប្រជារាស្ត្រ ។ ក្រោយមក **អន្តស៊ូ** (Nac Thu) ក៏មកសុំចំណុះទៀត ។ យួនក៏ដកថយទៅវិញអស់ (37) ។ ចំពោះព្រឹត្តិការណ៍បែបនេះ តើការពិតស្ថិតនៅត្រង់ណា? ឯកសារខ្មែរមិនឃើញនិយាយសោះ ។

## ៨. ព្រះបាទស្រីធម្មរាជាទី៣ (១៧០២-១៧០៣)

នៅគ.ស.១៧០២ ព្រះបាទ **ជ័យជេដ្ឋាទី៣** ដោយឃើញព្រះរាជបុត្រនាម **ធម្មរាជា** ដែលមានព្រះជន្មតែ ១២វស្សាមានឫកពាសមរម្យ ក៏បង្វែររាជ្យថ្វាយ ប៉ុន្តែមិនបានធ្វើពិធីរាជាភិសេកទេ ព្រោះមានវ័យនៅក្មេងពេក ។

គ្រានោះ មានសំរែម្នាក់ឈ្មោះ **គះស្រោវ៉ុខ** នៅស្រុក **ភុឡា** (ភូមា?) បានបះប្រឆាំងព្រះរាជា ។ ដោយមានការថ្វាយយោបល់ពីមន្ត្រីព្រះអង្គទ្រង់បញ្ជាអោយលើកទ័ពទៅបង្ក្រាបសំរែនោះបាននៅចុងខេត្តពោធិ៍សាត់ ហើយយកទៅបញ្ចូលជាពលរក្សាប្រាសាទនគរវត្ត ។

នៅគ. ស. ១៧០៣ ព្រះរាជាយាងពីពោធិ៍សាត់មកគង់នៅរាជធានី **ឧដុង្គ** វិញ ។ លុះគ្រងរាជ្យបាន ១ឆ្នាំ ព្រះអង្គទ្រង់លើករាជ្យថ្វាយទៅព្រះបិតាវិញ ។

## ៩. ព្រះបាទជ័យជេដ្ឋាទី ៣ (រជ្ជកាលទី ៥ : ១៧០៣-១៧០៦)

នៅគ. ស. ១៧០៤ រាជវង្សានុវង្សលាវមួយអន្លើដោយបរិវារ ៥០០០នាក់ បានភៀសមកសុំជ្រកកោននឹងព្រះរាជាខ្មែរ ។ ព្រះអង្គទ្រង់សព្វព្រះទ័យទទួលអោយទៅរស់នៅក្នុងខេត្ត **ឈនី** នៅជិតភូមិលាវដែលជាឈ្លើយខ្មែរតាំងពីសម័យលង្វែកម្ល៉េះ ។ឯហេតុដែលនាំអោយមានការភៀសខ្លួននោះ មកពីកាលណោះនៅរាជាណាចក្រ **វៀងចន្ទន៍** មានកើតចម្បាំងគ្នាឯងក្នុងស្រុកតាំងពីគ. ស. ១៧០០ម្ល៉េះ ។ ទេសាភិបាលក្រុង Nakhône ឈ្មោះ Nan Tharat បានបះដណ្តើមយករាជសម្បត្តិសោយ បណ្តាលអោយមានការវឹកវរក្នុងផ្ទៃប្រទេស ។

លុះព្រះរាជបុត្រមានព្រះជន្ម ១៦ វស្សាហើយ ព្រះរាជាដាក់រាជ្យថ្វាយម្តងទៀត ។

## ១០. ព្រះបាទធម្មរាជាទី ៣ (រជ្ជកាលទី ២ : ១៧០៦-១៧០៩)

ព្រះអង្គធ្វើពិធីអភិសេកឡើងសោយរាជ្យ ដោយមានព្រះនាមសំរាប់រាជ្យថា ព្រះ **ស្រីធម្មរាជាធិរាជរាមាធិបតីបរមបពិត្រ** ។ ឯព្រះបិតាដែលដាក់រាជ្យនោះទ្រង់មានឋានៈជាក្សត្រិយ៍ **ឧតយោរាជ** ។

នៅគ. ស. ១៧០៦ ព្រះម៉ែនាង **ស្រីបុប្ផា** ប្រសូតបុត្រនាម **អង្គអិម** ។

នៅគ. ស. ១៧០៧ ព្រះ **អង្គឆខ** មានបុត្រនាម **អង្គសួរ** ក្រោយមកមាននាមថា **ឧធ័យរាជា** ។ ចំណែកឯព្រះម្នាង **ជាតិក្សត្រី** មានបុត្រនាម **អង្គចន្ទ** (ឯកសារខ្លះហៅថា **ចៅពញាចន្ទ**) ក្រោយមកមាននាមហៅថា **បទុមរាជា** និងព្រះ **កែវហ្វា** ។

នៅគ. ស. ១៧០៧ ដដែល ដោយឃើញថាផ្ទៃក្នុងរបស់ខ្មែរនៅតែមានភាពច្របូកច្របល់ដដែល ចិនឈ្មោះ **ម៉ាកគីវ** បានលើកដង្វាយទៅថ្វាយសំដែងភក្តីភាពចំពោះស្តេច **ឡៀវ** ហើយទូលសុំធ្វើចៅហ្វាយខេត្ត **ពាម** ។ ស្តេច **ហៀន តុង** ទ្រង់យល់ព្រមតាមសំណើនោះ ។ ដូច្នេះ ចាប់ពីគ. ស. ១៧០៧ ភូមិភាគ **ពាម** ក៏បានក្លាយទៅជាសាមន្តរដ្ឋរបស់យួន ។ ពេលនោះ មានជនជាតិយួនបានចូលរស់រាយប៉ាយលើទឹកដីខ្មែរ ។ ស្តេច **ហៀន តុង** ទ្រង់ចាត់អោយសេនាទៅប្រមែប្រមូលពួកនោះ ចែកដីធ្លីអោយ

ដើម្បីបង្កើតភូមិ : លើកលែងមិនអោយបំពេញកិច្ចការខាងកំណែនផ្សេងៗ ខាងយោធាហើយមិនបាច់បង់ពន្ធក្នុងរយៈពេល ៣ឆ្នាំ ។

នៅគ.ស.១៧០៩ ព្រះម៉ែនាង **ស្រីបុន្នា** ប្រសូតបុត្រនាម **អង្គស្ងួន** ។ នាឆ្នាំនោះព្រះ **ធម្មរាជា** ដោយមានព្រះបំណងធ្វើការត្រួតពិនិត្យពួកលាវដែលបានភៀសខ្លួនមកនៅក្នុងខេត្ត **បាទី** នោះទ្រង់បញ្ជាអោយប្រមូលពួកនោះទៅរស់នៅមូលគ្គាង**កោះរាម**វិញ តែពួកនោះមិនយល់ព្រម បែរជាបះបោរប្រឆាំងនឹងព្រះរាជបញ្ជា ។ ព្រះរាជាទ្រង់បង្គាប់អោយលើកទ័ពទៅបង្ក្រាប បំបែកពួកនោះជា៣ក្រុម :

- ១ក្រុមរត់ទៅនៅព្រៃលើ
- ១ក្រុមរត់ទៅនៅស្រុកក្រោម
- ១ក្រុមរត់ទៅចូលព្រះ **កែវហ្វាអង្គអិម** ដែលត្រូវដាក់រាជ្យនៅ គ.ស.១៧០០នោះ ។ ស្តេចអង្គនេះទំនងជាមានគំនុំនឹងព្រះបិតុលា(ជ័យជេដ្ឋាទី៣) ក្នុងការដែលព្រះអង្គទ្រង់បានយករាជសម្បត្តិទៅវិញនោះ បានចូលដៃជាមួយស្តេចមួយអង្គទៀតនាម **សុគន្ធបទ** ហើយបំបះបំបោរពួកលាវដែលត្រូវបានយួនផ្តល់ជំនួយទ័ព២០០០០នាក់ ។ ម្យ៉ាងទៀត ព្រះ**អង្គអិម** ទ្រង់ចាត់អោយទៅបញ្ចុះបញ្ចូលរាស្ត្រព្រៃលើ មាន **ក្មួយ សំរែ** បានពល ១០០០០នាក់ទៀត លើកទៅវាយបានខេត្តខាងកើត រួចឆ្លងទន្លេយកទ័ពទៅឡោមព័ទ្ធវាំង **ឧដុង្គ** (គ.ស.១៧១០) ។ ក្រោយពីតស៊ូរយៈពេល ៣ខែ ព្រះ**ធម្មរាជា** បានភៀសព្រះអង្គទៅប្រទេសសៀមក្នុងពេលរាត្រីជាមួយនឹងព្រះ**អង្គធន**(បុត្រព្រះឧទ័យរាជាអង្គយ៉ង) និងព្រះរាជបុត្រព្រះអង្គ គឺ **អង្គអិម** ។

ដូច្នេះ នេះជាលើកទី ២ហើយដែលមានស្តេចខ្មែរបានរត់ទៅពឹងពាក់អោយសៀមជួយយកអាសា ។ ស្តេចទី ១គឺ **ចៅពញាចន្ទ** ឬ **ចន្ទរាជា** ។

## ១១. ព្រះកែវហ្វាទី៣ អង្គអិម (រជ្ជកាលទី២ : ១៧១០-១៧២២)

លុះព្រះ **ធម្មរាជា** ភៀសចេញទៅបាត់ហើយ មន្ត្រីទាំងឡាយក៏អញ្ជើញព្រះ**អង្គអិម** ឡើងគ្រងរាជ្យស្នងព្រះអនុជ ។ ប៉ុន្តែ ៤ឆ្នាំក្រោយមកទៀតទើបព្រះអង្គធ្វើពិធីអភិសេកដោយមានព្រះនាមសំរាប់រាជ្យថា **ព្រះអង្គអិមសម្តេចព្រះកែវហ្វា** ។

នៅគ.ស.១៧១៤ ព្រះចៅក្រុង **ស្រីអយុធ្យា** ទ្រង់ចាត់អោយមន្ត្រី២នាក់ គឺ **ចៅពញាពលទេព** និង **ពញាសតាវតី** ជាមួយនឹងកងទ័ព ១៥ ០០០នាក់នាំស្តេចទាំង៣អង្គមកចងស្ពានមេត្រី ។ ពេលយាងមកដល់ក្រុងបាត់ដំបង **សម្តេចព្រះកែវហ្វា** ព្រះអង្គមិនព្រមទទួលជាផ្លូវមេត្រី ក៏ត្រឡប់ទៅក្រុង **អយុធ្យា** វិញ ។

បន្ទាប់ពីនោះ **ព្រះកែវហ្វ៊ាអង្គអិម** ទ្រង់បានប្រគល់រាជសម្បត្តិអោយ **សម្តេចព្រះអគ្គមហេសី** ហើយទ្រង់ផ្នួសបាន ៣ ថ្ងៃ រួចព្រះអង្គលាផ្នួសវិញ ។

នៅគ.ស. ១៧១៥ ដោយមានការគាំទ្រពីព្រះចៅសៀមផង **ព្រះអង្គឯម** ត្រូវចាត់អោយលើកទ័ពចូលមកដល់ខេត្តពោធិ៍សាត់ ដែលមានប្រជារាស្ត្រភាគច្រើននៅស្រឡាញ់រាប់អានព្រះ **ធម្មរាជា** នៅឡើយ ។ លុះទ្រង់ទទួលពត៌មានថារាស្ត្រនៅពោធិ៍សាត់បះប្រឆាំងព្រះអង្គហើយ **ព្រះកែវហ្វ៊ាអង្គអិម** ទ្រង់បញ្ជាអោយទ័ពយួនលើកទៅវាយ ។ ព្រះ**អង្គឯម** ត្រូវរបួសថយទៅនៅ **ចូសរីសាញ** រង់ចាំជំនួយទ័ពមកពីប្រទេសសៀម ។

ពីគ.ស. ១៧១៩ ដល់ ១៧២២ ព្រះចៅសៀមទ្រង់បញ្ជាអោយលើកទ័ពជើងទឹក ៥០០០ នាក់ មកវាយខេត្ត **ពាម** និងទ័ពជើងគោក ១០០០០ នាក់ នាំព្រះ**ធម្មរាជា** និងព្រះរាជបុត្រត្រឡប់ចូលប្រទេសខ្មែរម្តងទៀត ។ ទ័ពជើងទឹករបស់សៀមត្រូវមេទ័ពជាតិចិនឈ្មោះ **ម៉ាក គីវ** វាយអោយថយទៅវិញ ប៉ុន្តែទ័ពជើងគោកបានជំរុលទៅដល់ក្រុង **ឧដុង្គ** ។

ដោយឃើញស្ថានភាពដុនដាបពេកហើយ ហើយក្រោយពីពិគ្រោះជាមួយពួកមន្ត្រី **សម្តេចកែវហ្វ៊ា** ទ្រង់ចាត់មន្ត្រីជាន់ខ្ពស់ម្នាក់ទៅធ្វើការចរចាជាមួយមេទ័ពសៀម សុំចងស្ពានមេត្រី ហើយព្រមនាំរាជសារជំបារមាសឡើងសៀមតាមទំនៀម ។ ដោយឃើញថា **ព្រះកែវហ្វ៊ា** ព្រមផ្តល់អត្ថប្រយោជន៍ច្រើនដល់ជាតិគេ សៀមក៏យល់ព្រម ហើយនាំស្តេចខ្មែរអភ័ព្វទាំង ៣ ត្រឡប់ចូលស្រុកសៀមវិញអស់ ។

## ១២. ព្រះបាទសត្ថាទី ២ អង្គជី (រជ្ជកាលទី ១ : ១៧២២-១៧២៩)

នៅគ.ស. ១៧២២ ព្រះ**កែវហ្វ៊ា អង្គអិម** ទ្រង់បង្វែររាជសម្បត្តិអោយរាជបុត្រនាម **អង្គជី** ។ ព្រះអង្គមាននាមសំរាប់រាជ្យថា **សម្តេចព្រះសត្ថា** សោយរាជ្យនៅក្រុង**ឧដុង្គ** លើក **សម្តេចព្រះស្រីសុជាតា** (បុត្រីព្រះជ័យជេដ្ឋា) ជាអគ្គមហេសី ។

ពេលនោះ ប្រជាជននៅនាងផ្អែកបះបោរប្រឆាំងនិងព្រះអង្គ ព្រះអង្គទ្រង់អោយលើកទ័ពទៅបង្រ្កាបរាបទាបបានវិញ ។

នៅគ.ស. ១៧២៩ **ព្រះសត្ថា** ទ្រង់លើករាជសម្បត្តិថ្វាយទៅព្រះបិតាវិញ ។ ព្រះអង្គក៏ព្រមទទួលឡើងសោយរាជ្យជាលើកទី ៣ ។

## ១៣. ព្រះកែវហ្វ៉ាទី៣ អង្គអិម (រជ្ជកាលទី៣: ១៧២៩)

ព្រះអង្គសោយរាជ្យបានតែ ៧ ខែ ហើយមានព្រះនាមសំរាប់រាជ្យថា **ព្រះបាទសម្តេចស្តេចព្រះជ័យជេដ្ឋាធិរាជរាមាឥស្សរកំពូលលោកីយត្រីត្រៃតាខនាថ** ។ នៅជំណាច់គ. ស. ១៧២៩ ព្រះអង្គទ្រង់បង្វែររាជ្យអោយព្រះរាជបុត្រសារជាថ្មីម្តងទៀត ។

## ១៤. ព្រះបាទសត្ថាទី ២ អង្គជី (រជ្ជកាលទី ២ : ១៧២៩-១៧៣៧)

ព្រះអង្គមាននាមសំរាប់រាជ្យថា **ព្រះបាទសម្តេចស្តេចព្រះរាជាឱង្ការព្រះបរមរាជាធិរាជរាមាធិបតី** ។ ព្រះបិតាទ្រង់ស្ថិតនៅជាឧភយោរាជ ។

នៅគ. ស. ១៧៣០ មានលាវម្នាក់នៅ **ប្រសូត បាត្តំ** តាំងខ្លួនជាអ្នកមានបុណ្យធម្មិកជន ។ មានខ្មែរជាច្រើនជឿតាម លាវនោះក៏លើកទៅវាយយួនរហូតដល់ **ព្រៃនគរ** ។ ស្តេច **ទុក តុង** (Tuc Tông) បញ្ជាអោយមេទ័ពឈ្មោះ **ត្រឿង ភឿក វិញ** (Truong-phuoc Vinh) លើកទ័ពទៅបង្ក្រាប(37) ។ពួកនោះបាក់ទ័ព ថយចូលស្រុកខ្មែរវិញ តែបានសម្លាប់រង្គាលជនជាតិយួនទាំងឡាយដែលខ្លួនបានជួបប្រទះ ។ លុះទ្រង់ជ្រាបពីឧប្បត្តិហេតុខាងលើនោះ **ព្រះសត្ថា** ទ្រង់បញ្ជាអោយលើកទ័ពទៅបង្ក្រាបអោយរាបទាបវិញអស់ ។ ប៉ុន្តែនៅឆ្នាំក្រោយ (គ. ស. ១៧៣១) យួនបានលើកទ័ពមកសងសឹកខ្មែររហូតដល់ក្រុងភ្នំពេញ ។ **ព្រះសត្ថា** ទ្រង់ថយទ័ពទៅនៅ **ពាមក្រែង** (ស្រីសឈរ)សិន ។ លុះកែនទ័ពបានគ្រប់ល្មមហើយ ព្រះអង្គទ្រង់លើកមកវាយយួន យួនថយទៅវិញអស់ ។

ក្រោយមក ស្តេចយួនបញ្ជាអោយលើកទ័ពមកច្រើនជាងមុនទៀត ។ **ព្រះសត្ថា**ទ្រង់ថយទៅគង់នៅ **ពាមជ្រោយ** (អាសន្ទុក) កែនទ័ពរួចលើកទៅប្រយុទ្ធនឹងយួន ។ ខ្មែរមានជ័យជំនះទៀត ។

ក្រោយពីនោះ **ព្រះសត្ថា** និងរាជវង្សានុវង្សយាងទៅគង់នៅលង្វែកវិញ ។

ចំពោះព្រឹត្តិការណ៍ខាងលើ ឯកសារយួន(37) បាននិយាយថា **ព្រះសត្ថា** ដោយខ្លាចមានទោសកំហុសធ្លាក់ទៅលើព្រះអង្គ ក៏បានថយទៅ **សឺន បូ** (Son-bô ?) ហើយទ្រង់ផ្ញើសារលិខិតទៅមេទ័ពយួនថា សុំអោយពន្យាពេលដើម្បីព្រះអង្គបង្ក្រាបជនបះបោរ ។ ប៉ុន្តែពួកបះបោរនៅតែបន្តសកម្មភាពសម្លាប់យួនដដែល ។ មេទ័ពយួនឈ្មោះ **ត្រឿង ភឿក វិញ** បានបន្ទោសព្រះសត្ថាថាចូលដៃនឹងពួកបះបោរ ។ ព្រះអង្គភិតភ័យខ្លាំងទ្រង់ថយទៅ **សឺនបួរ** (?) ទ្រង់បញ្ជាអោយយកវត្ថុមានតម្លៃទៅសូកប៉ាន់ដើម្បីទុកពេលអោយព្រះអង្គបង្ក្រាបពួកបះបោរ ។ ទ័ពយួនវាយលុកចូលដល់ Lôviet (អង្គរវត្ត) **ព្រះសត្ថា** ទ្រង់ប្រើឧបាយសម្លាប់បានពួកលាវបះបោរ រួចចេញសារភាពទទួលទោសនៅចំពោះទ័ពយួន ។ ទ័ពយួនក៏ដកថយវិញអស់ទៅ ។

ប្រភពយួនដដែលបានបញ្ជាក់ថា ក្រោយពីបានជ័យជំនះក្នុងការបង្ក្រាបពួកបះបោរនោះហើយ ស្តេចយួននាម **ទុក តុង** (Tuc-tông) តម្រូវអោយ **ព្រះសត្ថា** លើកអោយយួន ២ខេត្ត គឺ **ខេត្តមេសរ** និង **លង់ហោរ** (គ.ស. ១៧៣២) ដោយយកលេសថា ដើម្បីការពារជនជាតិយួនដែលបានទៅរស់នៅជាច្រើននៅត្រង់តំបន់នោះហើយ (42) ។

ដូច្នេះ ជនជាតិយួនបានចូលដល់ទន្លេមេគង្គ ហើយក្នុងដំណើរសំរុកមកទិសខាងត្បូងរបស់ខ្លួន ។ នៅក្នុង ខេត្ត **លង់ហោរ** យួនបានបង្កើតបន្ទាយ **ឡុង ហោ** (Long-hô) ចំណែកឯ **មេសរ** នៅរក្សាលក្ខន្តិកៈចាស់ដដែល ។

ចំណែកឯព្រះ **ធម្មរាជា** កាលដែលយាងទៅគង់នៅឯក្រុង **អយុធ្យា** ឯណោះ មានម្នាងសៀមឈ្មោះ **ម៉ម់តែ** ហើយមានបុត្រា២អង្គ និងបុត្រី១អង្គ គឺ :

- **អង្គហ៊ីង**
- **អង្គជួង**
- **អង្គសោតាក្សត្រី**

នៅគ.ស. ១៧៣៥ ព្រះអង្គទ្រង់ប្រទានដល់ព្រះរាជបុត្រ **អង្គអិម** នូវនាម **ធម្មរាជា** ដូចព្រះអង្គដែរ ។ បន្ទាប់មក ព្រះ**ធម្មរាជា** បុត្រទ្រង់បានសូមអនុញ្ញាតពីព្រះចៅសៀមអោយព្រះអង្គបានវិលត្រឡប់ចូលមាតុភូមិវិញ ដើម្បីគិតការដែនដី ។ លុះព្រះចៅសៀមទ្រង់បានយល់ព្រមតាមសំនើហើយ ព្រះអង្គក៏យាងទៅគង់ត្រង់តំបន់ **នគររាជសីមា** បញ្ជូនទូតទៅចរចាសុំចងស្ពានមេត្រីជាមួយ **ព្រះសត្ថា** តែពុំបានផលអ្វីសោះ ព្រះអង្គក៏គង់នៅ **នគររាជសីមា** នោះសិនទៅ ។

គួរគប្បីជ្រាបថានៅ គ.ស. ១៧៣៥ ដដែលនោះ ចិនឈ្មោះ **ម៉ាក គីវ** ដែលឈរត្រួតតំបន់មាត់សមុទ្រខ្មែរបានទទួលមរណភាព ។ ស្តេចយួននាម **ទុក តុង** (Tuc-tông) ទ្រង់លើកអោយកូនលោកឈ្មោះ **ម៉ាក ធៀន ទី** (Mâc Thiên Tu) ដែលមានម្តាយជាតិយួនឡើងកាន់តំណែងជាជំនួសឪពុក ។ កាលណោះ តំបន់ **ពាម** បានក្លាយទៅជាតំបន់ពាណិជ្ជកម្មមួយយ៉ាងសំខាន់ ។ ដោយហេតុនោះ ស្តេចយួនទ្រង់ប្រទានអោយសំពៅធំ៣គ្រឿងសំរាប់ទាក់ទងជាមួយនឹងបរទេស ។ មន្ត្រីថ្មីរូបនោះ ក៏បានកែនទ័ពសង់បន្ទាយ សង់ផ្សារ សង់ក្រុង ។ កប៉ាល់បរទេសចេញចូលធ្វើជំនួញកាន់តែច្រើនឡើងៗ ។ ចំណែកលោកក៏បានបញ្ជូនទំនិញចេញទៅលក់ដល់ប្រទេសជប៉ុនឯណោះ (37) ។

នៅគ.ស. ១៧៣៦ **ព្រះសត្ថា** ទ្រង់មានព្រះទ័យសង្ស័យលើរូបអគ្គមហេសីផ្ទាល់របស់ព្រះអង្គគឺ **សម្តេចព្រះស្រីសុជាតា** និងក្សត្របីអង្គគឺ ៖ **អង្គសូរ** (បុត្រព្រះអង្គឯម ដែលភៀសទៅសៀម) **អង្គស្ងួន** និង **អង្គចន្ទ** (បុត្ររបស់ព្រះធម្មរាជាទី៣ ដែលភៀសទៅសៀម) ថាមានគំនិតក្បត់ចំពោះព្រះអង្គ ទើបព្រះអង្គយាងទៅស្ថិតនៅក្រុងភ្នំពេញ ហើយបញ្ជាអោយមនុស្សមកព័ទ្ធដើម្បីធ្វើគុតស្តេច

ទាំង ៤អង្គនោះ ។ ប៉ុន្តែក្សត្រាទាំង៣អង្គ បានប្រមូលរាស្ត្រនៅក្រុងលង្វែក ហើយលើកមកប្រយុទ្ធនឹង **ព្រះសត្ថា** ហើយមានជ័យជំនះ ។ **ព្រះសត្ថា** ទ្រង់ភៀសព្រះអង្គទៅប្រទេសយួនជាមួយនឹងព្រះអនុជពៅនាម **អង្គអិម** (ឯកសារខ្លះថា**អង្គអ៊ីម**) នៅគ.ស.១៧៣៧ ។

បន្ទាប់ពីនោះ ក្សត្រទាំងបីអង្គទ្រង់បានចាត់វិធានការផ្សេងៗ ដើម្បីទប់ទល់នឹងការវិលត្រឡប់មកវិញរបស់ព្រះ**សត្ថា** ដែលគេជឿជាក់ថាមុខជាមានទ័ពយួនជួយជាមិនខាន ។ ម្ល៉ោះហើយ **ព្រះអង្គស្ងួន** យាងទៅគង់នៅ **បាភ្នំ** ត្រើយខាងកើត ឯព្រះ**អង្គចន្ទ** យាងទៅគង់នៅត្រើយខាងលិច រង់ចាំរាំងផ្លូវទ័ពយួនដែលនឹងលើកមកតាមផ្លូវទឹក ។

នៅពេលជាមួយគ្នានោះ **ព្រះធម្មរាជា** បុត្រ(អង្គអិម) ទ្រង់កែនពួកអ្នកស្រុកភ្នំនៅតំបន់ **នគររាជ** ហើយលើកមកយកខេត្ត **នគរវត្ត** បានយ៉ាងងាយ ។ ចំណែកឯព្រះចៅសៀម លុះទ្រង់ជ្រាបពីស្ថានការណ៍នៅស្រុកខ្មែរហើយ ទ្រង់បានអនុញ្ញាតអោយព្រះ**ធម្មរាជា** (បិតា) ត្រឡប់មកវិញ មកឡើងគោកនៅត្រង់ **កំពត** ជាមួយទ័ព៣០០០នាក់ និងអនុញ្ញាតអោយព្រះ**អង្គឧទ** លើកទ័ព២០០០នាក់ ឆ្ពោះទៅ **នគររាជ** ជាទីកន្លែងដែលព្រះអង្គកែនទ័ពបាន ៨០០នាក់ ជាបន្ថែមហើយលើកទៅជួយព្រះ **ធម្មរាជា** (បុត្រ) នៅ **នគរវត្ត** លុះបានជួបជុំគ្នាហើយ ក្សត្រទាំងពីរទ្រង់បានលើកចេញជា២ផ្លូវ មួយអង្គយាងតាមបឹង **ទន្លេសាប** មួយអង្គយាងតាមផ្លូវគោក ហើយទៅជួបគ្នានៅ **សំរោងសែន** ក្នុងខេត្ត **កំពង់លែង** ។

លុះទ្រង់ជ្រាបពត៌មាននោះហើយ ព្រះ**ស្រីសុជាតា** (អគ្គមហេសី **ព្រះសត្ថា**) ដែលជាអ្នកផ្តួចផ្តើមគំនិតរំលំព្រះស្វាមីនោះ ទ្រង់បានទាក់ទងជាមួយស្តេចខ្មែរដែលទើបតែយាងមកពីស្រុកសៀម ។ ក្រោយពីបានធ្វើការចរចាគ្នាហើយ ក្សត្រទាំងនោះទ្រង់បានព្រមព្រៀងគ្នាថាត្រូវតែលើករាជសម្បត្តិថ្វាយទៅព្រះ **ស្រីធម្មរាជាទី ៣**វិញ ។

## ១៥. ព្រះបាទធម្មរាជាទី៣ (រជ្ជកាលទី៣ : ១៧៣៨-១៧៤៧)

ព្រះអង្គទទួលព្រះនាមសំរាប់រាជ្យថា **ព្រះជ័យជេដ្ឋាធិរាជរាមាធិបតី** ។ រាជធានីតាំងនៅ **ឧដុង្គ** ។ ព្រះអង្គទ្រង់យក អ្នកម្នាង**ជាតិក្សត្រី** ជាព្រះអគ្គមហេសីព្រះនាមថា **សម្តេចព្រះជាតិក្សត្រី** ។

ឯកសារយួនមួយបាននិយាយថា លុះបានឡើងសោយរាជ្យហើយព្រះ **ធម្មរាជាទី ៣** (Nac Thâm) ទ្រង់បានបញ្ជារាជទូតអោយនាំគ្រឿងបណ្ណាការទៅថ្វាយស្តេច **ឌុក តុង** ស្តេចអង្គនេះទ្រង់បានយល់ព្រម ។ ចំណែកឯ**ព្រះសត្ថាទី ២** (Nac Tha) ដែលភៀសទៅស្រុកយួននោះ បានស្តេចយួនទុកអោយនៅជ្រកកោននៅ**យ៉ាឌិញ** រង់ចាំឱកាសល្អ ហើយបានគង់នៅទីនោះអស់ជាង ១០ឆ្នាំ (37) ។

ពេលដែល **ម៉ាក គីវ** ទទួលមរណភាពហើយ **ព្រះធម្មរាជាទី ៣** ទ្រង់គិតថានឹងមានលទ្ធភាពដណ្ដើមយកដីពាមមកវិញ ក៏លើកទ័ពទៅវាយនៅគ.ស. ១៧៣៩ ប៉ុន្តែត្រូវ **ម៉ាក ធៀន ធី** ជាកូនរុញច្រានមកវិញ (37) ។

ចំណែកព្រះ**អង្គធន** ឡើងជាមហាឧភយោរាជ ហើយក្រោយទ្រង់ទទួលព្រះនាមថា **សម្ដេចព្រះរាមាធិបតី** ។ ព្រះ**អង្គសួរ ឧទ័យរាជា** បានឡើងជាមហាឧបរាជ ។ ព្រះ**ធម្មរាជាទី ៣** ទ្រង់ផ្សំផ្គុំព្រះរាជបុត្រព្រះ**អង្គអិម** (ធម្មរាជា) ជាមួយបុត្រីព្រះអង្គ គឺ **អ្នកអង្គបែន** នាម សម្ដេច**ព្រះឯកក្សត្រី** ។ ព្រះអង្គថ្វាយព្រះនាមព្រះ**អង្គអិម** ថាសម្ដេច**ព្រះកែវហ្វា** ហើយទ្រង់ផ្សំផ្គុំជាមួយ **អ្នកអង្គចុស** (បុត្រីព្រះមហាឧភយោរាជ) ដែលទ្រង់មានព្រះនាមថា **សម្ដេចព្រះអនុជាតិក្សត្រី** ។ នៅគ.ស.១៧៣៩ ក្សត្រីអង្គនេះមានបុត្រនាមព្រះ **អង្គធន** ។ ព្រះឧបរាជយកព្រះអនុជព្រះ **សត្ថាទី ២** នាម **អង្គពៅ** ជាមហេសី ហើយមានបុត្រនាម **អង្គតន់** ។ ព្រះឧបរាជមានម្នាងម្នាក់ទៀត គឺ **អ្នកម្នាងរស់** មានបុត្រនាម **អង្គម៉ាន** និងបុត្រីនាម **អង្គម៉ី** ។

នៅគ.ស.១៧៤០ ព្រះរាជបុត្រនាម **អង្គស្ងួនសម្ដេចព្រះស្រីជ័យជេដ្ឋ** មានបុត្រ ២ អង្គ នាម **អង្គនន់** និង **អង្គជី** ។ ពីរឆ្នាំក្រោយមក **ព្រះអង្គនន់** ទ្រង់មាននាមថា **ព្រះរាមាធិបតី** ។

នៅគ.ស.១៧៤៣ **សម្ដេចព្រះកែវហ្វា អង្គចន្ទ** ទ្រង់អាពាធហើយសុគត ។ នាឆ្នាំដដែល ព្រះរាជាទ្រង់ប្រទានអោយព្រះរាជបុត្រ **អង្គហ៊ីង** នូវព្រះនាមថា **ព្រះស្រីសុរិយោពណ៌** ហើយទ្រង់ផ្សំផ្គុំនឹងព្រះ **អនុជាតិក្សត្រី** (អតីតអគ្គមហេសីព្រះ**កែវហ្វា**) ។ ឯ**ព្រះអង្គដួង** ទ្រង់បានទទួលព្រះនាមថា **ព្រះកែវហ្វា** ។ ម្នាងរបស់ព្រះអង្គនាមអ្នកម្នាង **ធា** (បុត្រីឧកញ៉ា **មាន់**) មានបុត្រីនាម **អង្គលី** ។

នៅគ.ស. ១៧៤៥ អ្នកម្នាង **ធា** មហេសី ព្រះ**កែវហ្វាអង្គដួង** បានប្រសូតបុត្រនាម **អង្គធម្ម** ។

ព្រះ**ធម្មរាជាទី ៣** ទ្រង់បានអាពាធហើយសោយទិវង្គតនៅគ.ស.១៧៤៧ ។

## ១៦. ព្រះបាទធម្មរាជាទី ៤ អង្គអិម (១៧៤៧)

ព្រះអង្គបានឡើងសោយរាជ្យស្នងព្រះបិតា តែបានតែ១ឆ្នាំ ក៏ត្រូវព្រះអនុជនាម**អង្គហ៊ីង** (ប្រសូតនៅស្រុកសៀម) អោយបក្សពួកធ្វើគុត ។ ពួកនាម៉ឺន និងព្រាហ្មណ៍បុរោហិតមិនពេញចិត្តនិងអំពើឧក្រិដ្ឋនេះ បានលើកព្រ ះ**អង្គធន** មហាឧភយោរាជអោយឡើងសោយរាជ្យ ។

## ១៧. ព្រះរាមាធិបតីទី៣ អង្គទង (រជ្ជកាលទី ១ : ១៧៤៧-១៧៤៨)

នៅគ.ស.១៧៤៧នេះទៀត លោក **ឧកញ៉ានរេន្ទតុក** ចៅហ្វាយស្រុកខេត្តបាសាក់ ដែលត្រូវយួនវាចេះតែរំលោភលើអំណាច និងលើទឹកដីរបស់លោក ក៏បានលើកទ័ពទៅប្រយុទ្ធនឹងពួកនោះ ។ ជ័យជំនះបានមកខាងខ្មែរ ពួកយួនក៏រត់ទៅជ្រកនៅកោះ **តាហុង** នៅក្នុងទន្លេមេគង្គ ។

នៅគ.ស.១៧៤៨ ដោយយកលេសថាដើម្បីបង្ក្រាបខ្មែរបះបោរដែលមាន **ឧកញ៉ានរេន្ទតុក** (យួនហៅ Sô liên-tôc) ជាអ្នកដឹកនាំនោះ ព្រះចៅក្រុងវេទ្រង់បញ្ជាអោយមេទ័ពឈ្មោះ **ង្វៀនហ៊ីវ យួន** (Nguyên Huu Doan) លើកទ័ពយួនដោយមានព្រះ**សត្ថាទី២** ចូលរួមផង មកច្បាំងឈ្នះ**ឧកញ៉ានរេន្ទតុក** ដុតបំផ្លាញសំពៅរបស់លោកនៅ **មេសរ** ហើយលើកទ័ពឆ្ពោះទៅដល់ក្រុងភ្នំពេញ ។ ហ្លួងបញ្ជាអោយ**ចៅហ៊្វាឯក** (យួនហៅ Châu Thuy Yêt) លើកទ័ពចេញទៅតទល់នឹងយួននៅត្រង់ **ច្រាំងចំរេះ** ។

ទ័ពខ្មែរទន់ដៃជាងត្រូវជកថយ យួនដេញតាមដល់ **ឧដុង្គ** ។ ហ្លួង ព្រះឧបរាជ និងព្រះ**អង្គស្ងួន** (ស្រីជ័យជេដ្ឋា) ភៀសព្រះអង្គទៅប្រទេសសៀម ។

## ១៨. ព្រះសត្ថាទី២ អង្គជី (រជ្ជកាលទី៣ : ១៧៤៩)

ឯកសារយួនថា ស្តេចយួនលើកអោយព្រះ **សត្ថាទី២** ឡើងសោយរាជ្យនៅ **ឧដុង្គ** ។ ការពិត គឺពួកមេទ័ពយួនជាអ្នកកាន់អំណាច : អំណាចហូតយកពន្ធដា អំណាចតែងតាំងនិងផ្លាស់ប្តូរចៅហ្វាយស្រុកខ្មែរ និងយកច្បាប់រដ្ឋបាលនៅក្រុង **វេ** មកអនុវត្តនៅស្រុកខ្មែរ ។

កាលណោះ មន្ត្រីខ្មែរម្នាក់គឺ **ឧកញ៉ាក្រឡាហោមឡិត** មានការឈឺចាប់យ៉ាងខ្លាំងចំពោះការត្រួតត្រារបស់បរទេស បានកែនទ័ពនៅខេត្តពោធិ៍សាត់ហើយលើកទៅប្រយុទ្ធនឹងយួននៅត្រង់វាល **ស្រាចអង្គាម** ។ ទ័ពយួនទទួលបរាជ័យជកថយទៅវិញ នាំទាំងព្រះ**សត្ថាទី២** និងក្សត្រាខ្លះទៀតត្រឡប់ទៅស្រុកយួនវិញ ។ ព្រះ**សត្ថា** ទ្រង់អាពាធ ហើយសុគតនៅកណ្តាលផ្លូវ ។

ចំណែកឯលោក **ឧកញ៉ាក្រឡាហោមឡិត** និងលោកចៅហ្វាយស្រុកខេត្ត **ពោធិ៍សាត់** បានរៀបចំប្រទេសអោយមានសន្តិភាពឡើងវិញ ។ រួចលោកចាត់អោយសេនាបតីទៅស្រុកសៀមសូមយាងហ្លួងត្រឡប់មកវិញ ។ ព្រះចៅសៀមទ្រង់អនុញ្ញាតអោយតែព្រះ **អង្គស្ងួន** មកមុន ឯហ្លួង និងឧបរាជ**ឧទ័យរាជា** ត្រូវឃាត់ទុកសិន ។

## ១៩. ព្រះបាទស្រីជ័យជេដ្ឋ អង្គស្ងួន (១៧៤៩- ១៧៥៥)

ព្រះ**អង្គស្ងួន** បានឡើងសោយរាជ្យនៅ **ឧដុង្គ** ដោយមានព្រះនាមសំរាប់រាជ្យថា **ព្រះបាទសម្តេចព្រះរាជាឱង្ការព្រះស្រីជ័យជេដ្ឋាធិរាជបរមបពិត្រ** ។

ដើម្បីតបស្នងសងគុណចំពោះលោក **ឧកញ៉ាសួគ៌ា** ចៅហ្វាយស្រុកពោធិ៍សាត់ដែលបានលើកកំចាត់ខ្មាំងសត្រូវនោះ ព្រះរាជាទ្រង់សព្វព្រះទ័យលើកលោកឡើងជា **ចៅហ្វ៊ាទឡ្ហៈ** ការតែងតាំងថ្មីនេះធ្វើអោយមន្ត្រីឯទៀតមិនពេញចិត្ត ទូលមួលបង្កាច់ថាចង់ក្បត់ ។ ម្ល៉ោះហើយព្រះរាជាក៏ជឿតាម រួចបញ្ជាអោយពួកចាមជ្វាយកទៅសម្លាប់ ។ លោក **ឧកញ៉ាសួគ៌ា** ដឹងខ្លួនទាន់ ក៏ភៀសទៅស្រុកសៀមបាត់ទៅ (១៧៥០) ។

នៅគ.ស. ១៧៥១ ព្រះចៅសៀមទ្រង់សព្វព្រះទ័យបើកអោយស្តេចខ្មែរដែលភៀសទៅនៅ គ.ស.១៧៤៨ នោះអោយត្រឡប់ចូលស្រុកវិញ ។ ហ្លួង និងរាជវង្សានុវង្សយាងមកដល់ខេត្ត **ក្រូច** ក៏ឈប់នៅទីនោះសិន ព្រោះនៅគ.ស. ១៧៥២ មានមន្ត្រីឈ្មោះ **ខ្សែត្រឯក** គិតយករាជ្យអោយព្រះ**អង្គតន់** រាជបុត្រព្រះឧបរាជ **ឧទ័យរាជា** ។ លោកបានយកអ្នកសិល្ប៍ឈ្មោះ **ស្ងួស** ធ្វើមេទ័ព តែត្រូវហ្លួងនៅខេត្ត **ក្រូច**ធ្វើកលចាប់បាន **ខ្សែត្រឯក** យកទៅសម្លាប់ចោល ។ ក្រោយមកអ្នកសិល្ប៍ **ស្ងួស** កូន **ខ្សែត្រឯក** និងមេម្នាក់ទៀតឈ្មោះ**អង្គលីរាជ**ត្រូវចាប់បានហើយត្រូវប្រហារជីវិតបង់ទាំងអស់ ។

នៅគ.ស.១៧៥៣ ព្រះឧបរាជ**ឧទ័យរាជា** ដែលចូលបួសនៅ **នគរវត្ត** កាលយាងមកស្រុកសៀមក៏សុគតនៅឆ្នាំនោះ ។ព្រះរាជបុត្រព្រះអង្គនាម **អង្គតន់** ទ្រង់យកព្រះនាមថា **ឧទ័យរាជា** ដូចព្រះបិតា ។ ឯ **អង្គហ៊ីង** បានឡើងជាមហាឧបរាជ ។

## ២០. ព្រះបាទរាមាធិបតីទី៣ អង្គទង (រជ្ជកាលទី២ : ១៧៥៦-១៧៥៧)

ព្រះបាទ **ស្រីជ័យជេដ្ឋ អង្គស្ងួន** សោយទិវង្គតនៅគ.ស.១៧៥៥ ។ ព្រះមហាឧបភយោរាជ **អង្គទង** ត្រូវបានពួកមន្ត្រី និងព្រាហ្មណ៍បុរោហិតលើកអោយឡើងសោយរាជ្យនៅគ.ស.១៧៥៦ ។

វិវាទរវាងព្រះឧបរាជ **អង្គហ៊ីង** និងព្រះ **ឧទ័យរាជា** បានកើតឡើង ។ ព្រះ**ឧទ័យរាជា** ទ្រង់ភៀសទៅនៅស្រុក **ពាម** ក្រោយមកទៅនៅខេត្ត **ព្រះត្រពាំង** ។ គ្រានោះ **ម៉ាកធៀនទី** កូន **ម៉ាកគីវ** បានជួយកែនទ័ព ហើយប្រគល់អោយមន្ត្រី៣នាក់លើកឆ្ពោះទៅ **ឧដុង្គ** ចំណែកព្រះ**ឧទ័យរាជា** បានលើកទ័ពជើងទឹកតាមទន្លេមេគង្គ មកដល់ភ្នំពេញ ព្រះអង្គទ្រង់បានទទួលដំណឹងថា ទ័ពព្រះអង្គបានវាយឈ្នះព្រះឧបរាជ ហើយព្រះឧបរាជក៏ភៀសទៅនៅខេត្ត **ព្រៃក្ដី** ហើយ ។ ព្រះ**ឧទ័យរាជា** ទ្រង់អោយលើកទ័ពដេញតាមចាប់បានព្រះឧបរាជហើយធ្វើគុតទៅ ។ រួចទ្រង់អោយចាប់**អង្គដួង** ជាអនុជ **អង្គហ៊ីង** ហើយ

ដែលរត់ទៅឬស យកទៅផ្សឹកហើយសម្លាប់ចោលទៀត ។ ចំណែកឯ **អន្តនន់** និង **អន្តជី** (បុត្រអង្គស្ងួន) ត្រូវបានលើកលែងទោសព្រោះនៅក្មេងពេក ។

ពេលនោះ ព្រះអនុជ **ជាតិក្សត្រី** អតីតអគ្គមហេសីព្រះឧបរាជកែនទ័ពច្បាំង នឹងព្រះ**ឧទ័យរាជា** នៅ **កំពង់តាគោ** តែត្រូវបរាជ័យ ។ ដោយហេតុនោះ **ហ្លួង**(អង្គទង) អគ្គមហេសីព្រះឧបរាជ និងក្សត្រីខ្លះភៀសទៅគង់នៅពោធិ៍សាត់ ។ នៅគ.ស.១៧៥៧ ហ្លួងទ្រង់សោយទិវង្គតនៅទីនោះ ។ ព្រះ **ឧទ័យរាជា** ទ្រង់បានបញ្ជាអោយលើកទ័ពទៅចាប់អគ្គមហេសីព្រះឧបរាជនិងបុត្រនាម **អន្តនង** នៅ**ចុះស្ទឹងសាញ** យកប្រហារជីវិតទាំងពីរអង្គ ។ ឯ**អន្តនន់** និង **អន្តជី** ដែលភៀសទៅនៅ កំពង់ស្វាយ ក៏ត្រូវបញ្ជាអោយចាប់ដែរ ។ នៅតាមផ្លូវ មានមន្ត្រីខ្លះបានពង្រត់**អន្តនន់** ទៅស្រុកសៀម ឯ**អន្តជី**ត្រូវនាំទៅ **ឧដុង្គ** ហើយត្រូវធ្វើគុត ។

គួរគប្បីជ្រាបថា នៅគ.ស.១៧៥៧ មុនពេលដែលសោយទិវង្គតទៅ ព្រះ**អន្តនងរាមាធិបតី** ទ្រង់បានយល់ព្រមលះបង់អោយយួននូវ ខេត្ត**ផ្សារដែក** ស្រុក២នៃខេត្ត **លង់ហោរ** (យួនហៅ Tâm Don និង Xuy Lap) និងខេត្ត **មាត់ជ្រូក** ។ មូលហេតុបណ្ដាលមកពីយួនបានបង្កើតអោយមានចលាចលនៅក្នុងខេត្តខ្មែរគឺ ខេត្ត **ត្រាំង** ខេត្ត **បន្ទាយមាស** និងខេត្ត **ព្រែកឫស្សី** ដែលជាកម្លាំងកៀបសង្កត់មកលើរាជការខ្មែរដែលកំពុងតែជួបប្រទះនូវស្ថានការណ៍លំបាក ព្រោះតែមានវិបត្តិជាទម្ងន់ក្នុងរាជវង្ស (9) (សូមមើលផែនទី) ។

## ២១. ព្រះបាទនារាយណ៍រាជាទី២ អង្គតន់ (១៧៥៨-១៧៧៥)

ព្រះឧបរាជ **ឧទ័យរាជា** បានឡើងសោយរាជ្យនៅ **ឧដុង្គ** ដោយមានព្រះនាមសំរាប់រាជ្យថា **ព្រះបាទសម្ដេចស្ដេចព្រះរាជាឱង្ការព្រះនារាយណ៍រាជាធិរាជ រាមាធិបតី ព្រះស្រីសុរិយោពណ៌** ។

លុះបានឡើងសោយរាជ្យនៅគ.ស.១៧៥៨ ស្ដេចអង្គនេះទ្រង់បានលើកអោយស្ដេចយួននាម**ថេតុង** (Thê-tông) នូវដីពីរខេត្តគឺខេត្ត **ព្រះត្រពាំង** និង ខេត្ត **ឃ្លាំង** ជាសគុណចំពោះជំនួយផ្សេងៗដែលយួនបានផ្ដល់អោយក្នុងជម្លោះរវាងរាជវង្សានុវង្សខ្មែរ (42) (សូមមើលផែនទី) ។

ក្រោយពីក្រុង **លង្វែក** ត្រូវបែកបាក់ដោយការវាយលុករបស់សៀម ទឹកដីខ្មែរមួយភាគធំនៅឯនាយភ្នំដងរែកត្រូវបាត់បង់ជាស្ថាពរ ។ ប៉ុណ្ណឹងហើយ អ្នកដឹកនាំជាតិខ្មែរនៅតែមិនទាន់ចេះទាញមេរៀនពីការបែកបាក់សាមគ្គីរវាងគ្នាឯងនៅឡើយ ។ ជម្លោះដណ្ដើមអំណាច ដណ្ដើមរាជសម្បត្តិមានរឹតតែច្រើនឡើង ហើយរឹតតែញឹកញាប់ឡើងជាហេតុបណ្ដាលអោយអ្នកជិតខាង ជាពិសេសជាតិយួនដែលបានក្លាយជាមហាអំណាចមួយក្រោយពីបានច្បាំងឈ្នះប្រទេសចាម្ប៉ា នោះ មានឱកាស និងមានលេសដើម្បីធ្វើអន្តរាគមន៍លូកដៃកកូរផ្ទៃក្នុងរបស់ខ្មែរតាមតែអំពើចិត្ត ។

អ្នកដឹកនាំជាតិក្នុងសម័យនោះ ពុំបានយកចិត្តទុកដាក់ចំពោះវាសនាប្រទេសជាតិចំពោះជីវភាពរបស់ប្រជារាស្ត្រ គឺថាពុំបានគិតដល់ប្រយោជន៍រួមទេ តែគិតធ្វើយ៉ាងណាអោយតែបានអំណាច បានយសសក្តិ បានរាជបល្ល័ង្ក បានស្នេហា បានប្រយោជន៍ផ្ទាល់ខ្លួនតែប៉ុណ្ណោះ ។ ម៉្លោះហើយ ក្នុងការធ្វើអោយសំរេចបំណងរៀងៗ ខ្លួន គេមិននិយមសម្របសម្រួលផ្សះផ្សារាជវង្សានុវង្សទេ គេសុខចិត្តកែនរាស្ត្រអោយបង្ហូរឈាមគ្នារួចរត់ទៅពឹងពាក់បរទេសជិតខាងអោយគេជួយគាំទ្រ អោយគេជួយជំនួយជាទ័ពយកមកជិះជាន់ស្រុកទេសខ្លួន យកមកកាប់សម្លាប់តែជាតិឯង ។

នៅទីបំផុត ខ្មែរទាំងសងខាងត្រូវទ្រុឌទ្រោមអស់ថាមពលតែរៀងខ្លួន ប្រយោជន៍ត្រូវបានទៅអ្នកជិតខាងដែលគេតែងតែទារយកសគុណពីជំនួយរបស់គេគ្រប់ប្រភេទក្នុងការជួយគាំទ្រស្តេចខ្មែរដែលកើតវិវាទនឹងគ្នា ។ ដោយហេតុនោះ ស្តេចខ្លះដូចជា **អង្គអិម កែវហ្វ៊ាទី៣** សុខចិត្តដាក់ប្រទេសចំណុះសៀម អោយតែសៀមទុកអោយព្រះអង្គបានសោយរាជ្យហើយនាំស្តេចជាគូបដិបក្ខត្រឡប់ទៅស្រុកវិញ ឬ **សត្ថាទី២ អង្គជី** សុខចិត្តយល់ព្រមអោយពួកយួនមកតាំងអំណាចត្រួតត្រាលើស្រុកខ្មែរអោយតែពួកនេះព្រមទទួលស្គាល់ព្រះអង្គជាព្រះមហាក្សត្រខ្មែរ និងស្តេចខ្លះទៀតបានយល់ព្រមលះបង់ទឹកដីអោយបរទេសដូចជាករណីរបស់ **នារាយណ៍រាជាអង្គតន់** ជាដើម ។

ក្នុងរយៈពេល ១៣៥ឆ្នាំសោះ គឺចាប់ពីគ.ស. ១៦២៣ ដល់ ១៧៥៨ **ខ្មែរត្រូវបាត់បង់ទឹកដីកម្ពុជាក្រោមទាំងមូល ដែលមានទំហំផ្ទៃប្រមាណជា ៦០ ០០០គ.ម.ក្រឡា** ។

ក្នុងការដណ្តើមយកទឹកដីខាងលើនេះ គេសង្កេតឃើញថាយួនបានអនុវត្តវិធី៣យ៉ាង ៖

- **វិធីទូត ឬ សន្តិវិធី :** វិធីនេះគេបានយកមកអនុវត្តមុនគេបង្អស់ ព្រោះពេលនោះ ទោះបីយួនច្បាំងឈ្នះចាមហើយតែនៅមិនទាន់លេបអស់ទឹកដីចាមនៅឡើយ ។ ស្តេចយួនបានបញ្ជូនទូតអោយមក សូមអនុញ្ញាតពីស្តេចខ្មែរអោយរាស្ត្រយួនចូលរកស៊ីក្នុងទឹកដីខ្មែរ ។ នេះជាវិធីមួយដែលយួនពុំបានប្រើជាមួយចាមទេ ព្រោះជាមួយចាមគេបានបញ្ជូនទ័ពមកវាយឈ្នះសិន ទើបបញ្ជូនរាស្ត្រមកតាមក្រោយ ។

- **វិធីយោធា :** យួនបានប្រើវិធីនេះ ដោយផ្តល់ជំនួយជាទ័ពដើម្បីជួយច្បាំងស្តេច ឬមន្ត្រីណាដែលបានរត់ទៅពឹងអោយគេជួយ (ករណីរបស់ឧកញ៉ានរិន្ទអិមនៅគ.ស.១៦៩៩) ឬដោយយកលេសថាការពារជនជាតិគេមករស់នៅលើដីខ្មែរក៏លើកទ័ពមកច្បាំងនឹងខ្មែរ ( ឧ. ការបះបោរប្រឆាំងយួនក្នុង គ.ស. ១៧៣០) ។

- **វិធីចិត្តសាស្ត្រ :** យួនប្រើវិធីនេះដោយធ្វើការបំបះបំបោរបង្កើតអោយមានចលាចល អោយមានអសន្តិសុខ គឺធ្វើយ៉ាងណាអោយរាជការខ្មែរទ្រាំមិនបានត្រូវលះបង់ទឹកដីអោយគេទៀត ។ វិធីនេះយួនក៏មានប្រើក្នុងការទទួលស្គាល់ ឬលើកស្តេចខ្មែរអង្គណាមួយអោយឡើងសោយរាជ្យ (ឧ. ករណីព្រះនារាយណ៍រាជាអង្គតន់) ។

គួរកត់សំគាល់ម្យ៉ាងទៀតថា ជនជាតិយួនគេបានសរសេរក្នុងសៀវភៅប្រវត្តិសាស្ត្ររបស់គេថា : "ការបញ្ចូលទឹកដីជាផ្លូវការក្នុងដែនទឹប្រទេសគេ និងការដាក់អាជ្ញាធរអោយត្រួតត្រាច្រើនតែបានប្រព្រឹត្តក្រោយពេលដែល ជនជាតិយួនបានទៅនៅកុះករនៅលើទឹកដីនោះហើយ ។ ជនជាតិយួនជាមនុស្សឧស្សាហ៍ ព្យាយាមក្នុងការរកស៊ី ហើយម្យ៉ាងទៀតដោយមានវប្បធម៌ មានទំនៀមទំលាប់ខុសគ្នាផង បានជាកន្លែងណាដែលមានជនជាតិយួនទៅនៅហើយ ជនជាតិខ្មែរក៏បោះបង់ចោលទីនោះដើម្បីទៅរស់នៅកន្លែងដទៃវិញ ។ មានកន្លែងខ្លះ មានខ្មែរ និងយួននៅលាយឡំគ្នាដែរ ។ កាលណាមានជនជាតិយួនទៅរស់នៅកន្លែងណាបានច្រើនគ្នាហើយ ពួកស្តេច **ឡៀង** ក៏រកមធ្យោបាយដណ្តើមយកទឹកដីកន្លែងនោះជាផ្លូវការ និងដាក់អាជ្ញាធរអោយនៅត្រួតត្រាតទៅ " (37) ។

## បញ្ជីស្តេចខ្មែរសោយរាជ្យពីគ.ស. ១៦០៣ ដល់ ១៧៥៨

| លេខរជ្ជកាល | នាមសំរាប់រាជ្យ នាមផ្ទាល់ | កាលកំណត់រជ្ជកាល | រាជធានី | រាជវង្ស |
|---|---|---|---|---|
| ១ | បរមរាជាទី ៨ ស្រីសុរិយោពណ៌ | ១៦០៣-១៦១៨ | កោះស្លាកែតល្វាឯម | បុត្រព្រះបរមរាជាទី ៤ |
| ២ | ជ័យជេដ្ឋាទី ២ | ១៦១៨-១៦២៨ | ឧដុង្គ | បុត្រស្តេច ១ |
| ៣ | ធម្មរាជាទី ២ ឬ រាជសំភារ ចៅពញាតូ | ១៦២៩-១៦៣៤ | កោះឃ្លោក | បុត្រស្តេច ២ |
| ៤ | អង្គទងរាជា ចៅពញានូ | ១៦៣៥-១៦៣៩ | ឧដុង្គ | បុត្រស្តេច ២ |
| ៥ | បទុមរាជាទី ១ អង្គនន់ | ១៦៣៩-១៦៤១ | ឧដុង្គ | បុត្រព្រះឧទ័យ |
| ៦ | រាមាធិបតីទី ១ ចៅពញាចន្ទ | ១៦៤១-១៦៥៩ | ឧដុង្គ | បុត្រស្តេច ២ |
| ៧ | បរមរាជាទី ៩ អង្គសូរ | ១៦៥៩-១៦៧២ | ឧដុង្គ | បុត្រព្រះឧទ័យ |
| ៨ | បទុមរាជាទី ២ ស្រីជ័យជេដ្ឋ | ១៦៧២-១៦៧៣ | ឧដុង្គ | បុត្រស្តេច ៥ |
| ៩ | កែវហ្វាទី ២ អង្គជី | ១៦៧៣-១៦៧៥ | ឧដុង្គ | បុត្រស្តេច ៧ |

| លេខរជ្ជកាល | នាមសំរាប់រាជ្យ នាមផ្ទាល់ | កាលកំណត់រជ្ជកាល | រាជធានី | រាជវង្ស |
|---|---|---|---|---|
| ១០[១] | ជ័យជេដ្ឋាទី ៣ អង្គស៊ូ ឬចៅពញាសូរ | ១៦៧៥-១៦៨៨ (រជ្ជកាលទី ១) | ឧដុង្គ ទ្រនំជ្រឹង | បុត្រស្តេច ៧ |
| ១១ | អ្នកម្នាងទៃ | ១៦៨៨ (៣ ខែ) | ឧដុង្គ | មាតាស្តេច ១០ |
| ១០[២] | ជ័យជេដ្ឋាទី ៣ | ១៦៨៨-១៦៩៥ (រជ្ជកាលទី ២) | ឧដុង្គ | បុត្រស្តេច ៧ |
| ១២ | រាមាធិបតីទី ២ ឧទ័យរាជា អង្គយ៉ង | ១៦៩៥-១៦៩៦ | ឧដុង្គ | បុត្រស្តេច ៩ |
| ១០[៣] | ជ័យជេដ្ឋាទី ៣ | ១៦៩៦-១៦៩៩ (រជ្ជកាលទី ៣) | ឧដុង្គ | បុត្រស្តេច ៧ |
| ១៣[១] | កែវហ៊្វាទី ៣ អង្គអិម | ១៦៩៩-១៧០០ (រជ្ជកាលទី ១) | រាំងភាក់ ពោធិ៍សាត់ | បុត្រអង្គនន់ |
| ១០[៤] | ជ័យជេដ្ឋាទី ៣ | ១៧០០-១៧០២ (រជ្ជកាលទី ៤) | ឧដុង្គ | បុត្រស្តេច ៧ |
| ១៤[១] | ធម្មរាជាទី ៣ | ១៧០២-១៧០៣ (រជ្ជកាលទី១) | ពោធិ៍សាត់ ឧដុង្គ | បុត្រស្តេច ១០ |
| ១០[៥] | ជ័យជេដ្ឋាទី ៣ | ១៧០៣-១៧០៦ (រជ្ជកាលទី ៥) | ឧដុង្គ | បុត្រស្តេច ៧ |
| ១៤[២] | ធម្មរាជាទី ៣ | ១៧០៦-១៧០៩ (រជ្ជកាលទី ២) | ឧដុង្គ | បុត្រស្តេច ១០ |
| ១៣[២] | កែវហ៊្វាទី ៣ អង្គអិម | ១៧១០-១៧២២ (រជ្ជកាលទី ២) | ឧដុង្គ | បុត្រអង្គនន់ |
| ១៥[១] | សត្ថា ទី ២ អង្គជី | ១៧២២-១៧២៩ (រជ្ជកាលទី ១) | ឧដុង្គ | បុត្រស្តេច ១៣ |

| លេខរជ្ជកាល | នាមសំរាប់រាជ្យ<br>នាមផ្ទាល់ | កាលកំណត់រជ្ជកាល | រាជធានី | រាជវង្ស |
|---|---|---|---|---|
| ១៣[៣] | កែវហ្វាទី ៣ ជ័យជេដ្ឋា<br>អង្គអិម | ១៧២៩ (៧ ខែ)<br>(រជ្ជកាលទី ៣) | ឧដុង្គ | បុត្រអង្គនន់ |
| ១៥[២] | សត្ថាទី ២ បរមរាជា<br>អង្គជី | ១៧២៩ - ១៧៣៧<br>(រជ្ជកាលទី ២) | ឧដុង្គ<br>លង្វែក | បុត្រស្តេច ១៣ |
| ១៤[៣] | ធម្មរាជាទី ៣ ជ័យជេដ្ឋា | ១៧៣៨ - ១៧៤៧<br>(រជ្ជកាលទី ៣) | ឧដុង្គ | បុត្រស្តេច ១០ |
| ១៦ | ធម្មរាជាទី ៤<br>អង្គអិម | ១៧៤៧<br>(១ ឆ្នាំ) | ឧដុង្គ | បុត្រស្តេច ១៤ |
| ១៧[១] | រាមាធិបតីទី ៣<br>អង្គទង | ១៧៤៧ - ១៧៤៨<br>(រជ្ជកាលទី ១) | ឧដុង្គ | បុត្រស្តេច ១២ |
| ១៥[៣] | ព្រះសត្ថាទី ២<br>អង្គជី | ១៧៤៩<br>(រជ្ជកាលទី ៣) | ឧដុង្គ | បុត្រស្តេច ១៣ |
| ១៨ | ស្រីជ័យជេដ្ឋា<br>អង្គស្ងួន | ១៧៤៩ - ១៧៥៥ | ឧដុង្គ | បុត្រស្តេច ១៤ |
| ១៧[២] | រាមាធិបតីទី ៣<br>អង្គទង | ១៧៥៦ - ១៧៥៧<br>(រជ្ជកាលទី ២) | ឧដុង្គ<br>ពោធិ៍សាត់ | បុត្រស្តេច ១២ |
| ១៩ | នារាយណ៍រាជាទី ២<br>ឧទ័យរាជា អង្គតន់ | ១៧៥៨ - ១៧៧៥ | ឧដុង្គ | ចៅស្តេច ១៧ |

**សេចក្តីសង្កេត** : លេខតូចដែលដាក់ក្បែរហើយនៅខាងស្តាំលើនៃលេខធំជាលេខសំគាល់ទីនៃរជ្ជកាល ។